

# សេចក្តីថ្លែងការណ៍ និងការអធិប្បាយ
# របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា
# ស្តីពីផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា
# និង សាធារណរដ្ឋសង្គមនិយមវៀតណាម

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍ពិសេស

## របស់

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា

# ស្តីពីផែនទីព្រំដែនរដ្ឋ

## រវាង

## ព្រះរាជាណាចក្រកម្ពុជា

## និង

## សាធារណរដ្ឋសង្គមនិយមវៀតណាម

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ បងប្អូនជនរួមជាតិជាទីគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅ។ ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីត្រូវការចាំបាច់ក្នុងការធ្វើសេចក្តីថ្លែងការណ៍ ដើម្បីបំភ្លឺជូនដល់ព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិគ្រប់រូប អំពីផែនទីព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានក្លាយជាប្រធានបទនយោបាយដ៏ក្តៅគគុក ប្រកបដោយគ្រោះថ្នាក់សម្រាប់ប្រជាជាតិនាពេលថ្មីៗនេះ។ ជាការពិត បញ្ហាព្រំដែនគឺជាកិច្ចការដ៏មានសារសំខាន់ ជាអាយុជីវិតរបស់ប្រទេសជាតិ ហើយក៏ជាបញ្ហានយោបាយដ៏រសើបបំផុត ដែលអ្នកនយោបាយមួយចំនួនតែងលើកយកធ្វើជាប្រធានបទសម្រាប់ឃោសនាញុះញង់ឥតឈប់ឈរតាម រយៈមធ្យោបាយប្រជាភិថុតិ ដើម្បីបំភាន់សាធារណៈមតិជាតិ និងអន្តរជាតិ ហើយអូសទាញបោកបញ្ឆោតទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនជនរួមជាតិខ្មែរ ដើម្បីវាយប្រហារមកលើរាជរដ្ឋាភិបាល ក្នុងគោលបំណងកេងចំណេញយកផលប្រយោជន៍ខាងនយោបាយ។ ច្បាស់ណាស់ថា ការស្នេហាជាតិ និងទឹកដី ពុំមែនជាសិទ្ធិផ្តាច់មុខរបស់បុគ្គល ឬគណបក្សនយោបាយណាមួយតែឯងនោះទេ។ កិច្ចការពារអធិបតេយ្យ និងបូរណភាពទឹកដីរបស់ជាតិគឺជាសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ហើយរាជរដ្ឋាភិបាលតែងតែចាត់ទុកការងារនេះជាភារកិច្ច និងអាទិភាពដ៏សំខាន់ជាងគេបង្អស់របស់ខ្លួន និងតែងប្រកាន់ខ្ជាប់ខ្ជួននូវស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដើម្បីកសាងខ្សែបន្ទាត់ព្រំដែនមួយដែលមានភាពច្បាស់លាស់ត្រឹមត្រូវ ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍជាមួយប្រទេសជិតខាង និងធានាឱ្យបានដាច់ខាតថា បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាមិនបាត់បង់ឡើយ សូម្បីតែមួយម៉ែត្រក្រឡាក៏ដោយ។

ក្នុងស្មារតីនេះ ក៏ដូចជាក្នុងគោលដៅបញ្ជាក់ឱ្យឃើញអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានេះ ក្នុងឋានៈជាប្រមុខនៃរាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភា ខ្ញុំព្រះករុណាខ្ញុំ បានចំណាយពេលអស់ជាងប្រាំម៉ោង ដើម្បីធ្វើបទអន្តរាគមន៍បកស្រាយ និងផ្តល់ការបំភ្លឺគ្រប់ជ្រុងជ្រោយជូនដល់រដ្ឋសភា និងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសអំពីការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៥។ ក៏ប៉ុន្តែ ថ្វីត្បិតតែមានការពន្យល់បកស្រាយច្បាស់លាស់រួចហើយ ហើយបទអន្តរាគមន៍នោះក៏ត្រូវបានយកមករៀបចំបោះពុម្ពចែកផ្សាយជាសៀវភៅផង និងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមបណ្តាញអ៊ីនធឺណែត និងបណ្តាញព័ត៌មាននានាផងក្តី ក៏អ្នកនយោបាយប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួននូវតែបន្តធ្វើជាមិនដឹងមិនយល់ដដែល។ លើសពីនេះទៀត ពួកគេបាននឹងកំពុងបន្តឃោសនាបំផុសបំផុល បំភ្លៃ បំភ្លើស និងកាឡៃការពិត និងសភាពការណ៍ទាក់ទងនឹងបញ្ហាព្រំដែនជាមួយវៀតណាម ប្រកបដោយឧបាយកលទុច្ចរិត ឥតអៀនខ្មាស់ ក្នុងគោលដៅបង្កើតឱ្យមានការភាន់ច្រឡំ និងការយល់ដឹងមិនត្រឹមត្រូវលើបញ្ហាព្រំដែននេះ ហើយបោកបញ្ឆោតធ្វើអាជីវកម្មលើទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនប្រជាពលរដ្ឋខ្មែរ ចំពោះជាតិមាតុភូមិជាទីស្នេហារបស់ខ្លួន ដើម្បីកេងយកផលចំណេញនយោបាយ ដោយមិនខ្វាយខ្វល់ និងគ្មានការទទួលខុសត្រូវ ចំពោះជោគវាសនា និងផលប្រយោជន៍របស់ ប្រទេសជាតិឡើយ។

ជាការពិត ប្រវត្តិសាស្ត្រតំបន់ និងពិភពលោក ជាពិសេសបទពិសោធន៍ផ្ទាល់របស់កម្ពុជាបានបង្ហាញឱ្យឃើញច្បាស់ហើយថា ការលើកយកបញ្ហាព្រំដែននេះមកធ្វើអាជីវកម្មកេងចំណេញខាងនយោបាយ ដោយ

គ្មានការទទួលខុសត្រូវ ដើម្បីបម្រើឱ្យផលប្រយោជន៍នយោបាយរបស់បុគ្គលណាម្នាក់ ក្រុមណាមួយ ឬគណបក្សណាមួយ តាមរយៈការប្រើមធ្យោបាយប្រជាភិថុតិ ដើម្បីបំភាន់សាធារណៈមតិជាតិ និងអន្តរជាតិ អាចនឹងនាំមកគ្រោះថ្នាក់ដ៏ធំធេងសម្រាប់ប្រទេសជាតិ និងប្រជាជនទៅវិញទេ។ ជាពិសេសការបែកបាក់សាមគ្គីជាតិ និងឯកភាពជាតិ ការបង្កអាភិភាពជាតិសាសន៍ និងការបង្កការខូចខាតដល់ទំនាក់ទំនងមិត្តភាព សហប្រតិបត្តិការ និងអ្នកជិតខាងល្អ រវាងប្រទេសជិតខាងជាប់ព្រំដែនគ្នា។

យ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ គណបក្សប្រឆាំង តាមរយៈអ្នកនយោបាយមួយចំនួនរបស់ខ្លួន បានលើកយកបញ្ហាព្រំដែនមកធ្វើជាអាជីវកម្មជាថ្មីម្តងហើយម្តងទៀត ដោយធ្វើការចោទប្រកាន់ និងមួលបង្កាច់ ក្នុងល័ក្ខខ័ណ្ឌកាន់តែស្រួចស្រាល់ និងកាន់តែពិសពុល ដោយមិនខ្លាចញញើតច្បាប់រដ្ឋ និងគ្មានស្មារតីទទួលខុសត្រូវបន្តិចណាទាល់តែសោះ។ ពួកគេបានចោទប្រកាន់ និងមួលបង្កាច់មកលើរដ្ឋាភិបាលថា បានប្រើប្រាស់ផែនទីក្លែងក្លាយ ឬផែនទីមិនត្រឹមត្រូវ ឬផែនទីចោរ ក្នុងការកំណត់ព្រំដែនជាមួយប្រទេសវៀតណាម ហើយថែមទាំងបានលើកយកសន្ធិសញ្ញាឆ្នាំ១៩៧៩ ក្លែងក្លាយមកប្រើប្រាស់ ដោយឥតញញើត និងចោទប្រកាន់ដោយអយុត្តិធម៌បំផុតមកលើរដ្ឋរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ពិសេសថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា ថាបានសម្រេចរំលោយព្រំដែនជាតិជាមួយប្រទេសវៀតណាម ក្នុងគោលដៅញុះញង់ បង្កើតកំហឹងក្នុងចំណោមប្រជាពលរដ្ឋ បង្កការបែកបាក់សាមគ្គីជាតិ និងឯកភាពជាតិ ព្រមទាំងបង្កអាភិភាពជាតិសាសន៍ ដែលអាចបណ្តាលឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ប្រសិនមិនត្រូវបានទប់ស្កាត់ទាន់ពេលវេលានោះទេ។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ បងប្អូនជនរួមជាតិជាទីស្រឡាញ់ ខ្ញុំព្រះករុណាខ្ញុំ សូមបកស្រាយបញ្ហានេះបន្តិច ប្រគេនចំពោះព្រះសង្ឃ ក៏ដូចជាបងប្អូនជនរួមជាតិថា ប្រសិនបើការក្លែងបន្លំទាក់ទិនជាមួយនឹងបញ្ហាការក្លែងសន្ធិសញ្ញាឆ្នាំ១៩៧៩ ដែលថាកម្ពុជា និងវៀតណាម សម្រេចរំលោយព្រំដែនជាតិនោះ។ តើផលពិបាកវានឹងកើតមានអ្វីខ្លះ ប្រសិនបើយើងមិនចាត់វិធានការភ្លាមៗទាន់ពេល តាមរយៈនៃការអនុវត្តវិធានការច្បាប់ទៅលើសមាជិកព្រឹទ្ធសភាម្នាក់ ហើយឥឡូវនេះ គូកនរបស់គេកំពុងគេចខ្លួនទៅកាន់ប្រទេសថៃ ហើយយើងក៏កំពុងស្វែងរកដើម្បីយកពួកគេមកទទួលទោសតាមផ្លូវច្បាប់។ ខ្ញុំព្រះករុណាប៉ាន់ស្មានថា ប្រសិនបើមិនចាត់ការបន្ទាន់ ហើយរកមិនឃើញ ទុកឱ្យមានការសាបព្រួសនូវល្បិចដ៏គ្រោះថ្នាក់នេះ ទឹកចិត្តស្នេហាជាតិដ៏បរិសុទ្ធរបស់ប្រជាពលរដ្ឋត្រូវបានពុះកញ្ជ្រោលឡើង ពេលនោះអាចនិយាយបានថា សង្គ្រាមផ្ទៃក្នុងក៏អាចកើត និងសង្គ្រាមទល់ដែនក៏អាចកើត។ ករណីនេះមានឧទាហរណ៍កាលពីឆ្នាំ២០០៨ នៅក្នុងព្រះរាជាណាចក្រថៃ មានក្រុមនិយមជ្រុលមួយក្រុម ទាំងអ្នកនយោបាយ និងក្រុមអ្នកបម្រើនយោបាយ គេបានយកបញ្ហាព្រះវិហារជាចំណាប់ខ្មាំងខាងនយោបាយ មិនខុសពីអ្នកនយោបាយនៅកម្ពុជា ដែលបានប្រើប្រាស់បញ្ហាព្រំដែនកម្ពុជា-វៀតណាម ជាចំណាប់ខ្មាំងខាងនយោបាយ ដើម្បីបំផ្លាញបក្សកាន់អំណាចនោះទេ។ ជាលទ្ធផល មកដល់ពេលនេះ នៅក្នុងប្រទេសថៃ មានការបែកបាក់មិនទាន់ដល់ទីបញ្ចប់ទេ ជម្លោះផ្ទៃក្នុងរវាងលឿង ក្រហម និងចម្រុះពណ៌ រហូតដល់រដ្ឋប្រហារយោធា មិនទាន់ត្រូវបានដោះស្រាយនៅក្នុងប្រទេសថៃនៅឡើយ។ សង្គ្រាមទល់ដែនជាមួយកម្ពុជា ពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១១ ទើបតែត្រូវបានបញ្ចប់តាមរយៈសាលដីកាតុលាការឡាអេឆ្នាំ២០១៣តែប៉ុណ្ណោះ។ នេះហើយជាលទ្ធផលនៃភាពនិយមជ្រុល។ នៅក្នុងប្រទេសណាក៏ដោយ បើសិនមានស្ថានភាពបែបនេះ វាច្បាស់ជាបានកើតរឿងរ៉ាវប្រហាក់ប្រហែលគ្នា។

ខ្ញុំព្រះករុណាខ្ញុំ សូមទូលបង្គាញចំពោះព្រះតេជគុណគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិឱ្យបានជ្រាបថា កុំថាឡើយដល់ទៅរដ្ឋអធិបតេយ្យ សូម្បីតែរដ្ឋក្រោមអាណានិគម រហូតទៅដល់កុលសម្ព័ន្ធ ក៏សុទ្ធតែមានការកំណត់ព្រំប្រទល់ដូចគ្នា។ យើងជារដ្ឋអធិបតេយ្យ គឺមានព្រំដែនរដ្ឋ តាំងពីពេលដែលក្រោយបានឯករាជ្យ **សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនៈកោដ្ឋ** ព្រះអង្គបានខិតខំធ្វើការតស៊ូទាក់ទងទៅលើបញ្ហានេះ។ ទោះបីជាមុនបានឯករាជ្យ នៅក្រោមអាណានិគមបារាំង ក៏ពេលនោះមានការបែងចែកព្រំដែនរដ្ឋរវាងយើងជាមួយថៃ រវាងយើងជាមួយឡាវ រវាងយើងជាមួយកូសាំងស៊ីន ហើយនឹងមួយភាគរវាងព្រំប្រទល់រដ្ឋបាលរវាងយើងជាមួយវៀតណាម។ កុំថាឡើយដល់រដ្ឋអធិបតេយ្យ រដ្ឋអាណានិគម សូម្បីតែកុលសម្ព័ន្ធពីសម័យដើមក៏មានការកំណត់នូវព្រំប្រទល់នៃការគ្រប់គ្រងផងដែរ។ កុំនិយាយដល់រដ្ឋ ហើយកុំនិយាយដល់កុលសម្ព័ន្ធកាលពីសម័យដើម សូម្បីតែនៅក្នុងប្រទេសមួយក៏មានព្រំប្រទល់ខេត្ត ព្រំប្រទល់ស្រុក ព្រំប្រទល់ឃុំ ព្រំប្រទល់ភូមិ ហើយក្រុមគ្រួសារនីមួយៗសុទ្ធតែមានប្លង់ដីរឹងផងដែរ។ ចុះហេតុអ្វីបានជាអ្នកនយោបាយក្នុងបក្សប្រឆាំងមិនញញើតញញើម ហើយហ៊ានបង្ហោះចេញនូវឯកសារក្លែងក្លាយថាកម្ពុជា និងវៀតណាមបានឯកភាពគ្នារំលាយចោលនូវព្រំដែនរដ្ឋ។ នេះជាគ្រោះថ្នាក់ដ៏ធំធេង បើសិនរាជរដ្ឋាភិបាលមិនចាត់វិធានការបន្ទាន់ សង្គ្រាមផ្ទៃក្នុងនឹងអាចផ្ទុះឡើង តាមរយៈស្មារតីស្នេហាជាតិដ៏បរិសុទ្ធរបស់ជនជាតិខ្មែរយើង រាប់ទាំងខ្ញុំព្រះករុណាខ្ញុំក៏ប្រឆាំងជំទាស់ជាមួយនឹងការរំលាយព្រំដែនរដ្ឋដែរ ប្រសិនបើវាមែន ក៏ប៉ុន្តែរឿងនេះវាអត់ទាល់តែសោះ ហើយចុងសតវត្សទី២០ទៅហើយ តើវាអាចមានរឿងនេះកើតឡើងឬទេ។ ដូច្នេះ ការចាត់វិធានការបន្ទាន់ ឥឡូវយើងកំពុងស្វែងរកនូវការបង្ហោះតាម Facebook មួយចំនួនផ្សេងទៀត ដែលទាក់ទងទៅនឹងការបំភ្លៃទៅលើរឿងនេះ ហើយក៏សុំអំពាវនាវដល់អ្នកដែលកំពុងភៀសខ្លួនទៅកាន់ទីក្រុងបាងកក សូមវិលត្រឡប់មកទីក្រុងភ្នំពេញ ដើម្បីចូលខ្លួនសម្រាប់សារភាពជាមួយអាជ្ញាធរ ដែលខ្លួនបានរួមគំនិតបង្ហោះចេញនូវ Facebook របស់សមាជិកព្រឹទ្ធសភារូបនេះ។ ចំពោះមុខឧបាយកលដ៏ទុច្ចរិតនេះ និងក្នុងបំណងបញ្ចៀសកុំឱ្យបងប្អូនប្រជាពលរដ្ឋខ្មែរចាញ់ឧបាយកលបោកបញ្ឆោតរបស់អ្នកនយោបាយអគតិទាំងនោះ និងក្លាយទាំងមិនដឹងខ្លួនទៅជាឧបករណ៍អាជីវកម្មនយោបាយរបស់គេ ដោយសារតែទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូន។ រាជរដ្ឋាភិបាលកម្ពុជាដែលតែងប្រកាន់ភ្ជាប់នូវឆន្ទៈស្នេហាជាតិ ស្មារតីនៃការទទួលខុសត្រូវខ្ពស់ និងការប្តេជ្ញាចិត្តដ៏មោះមុតឥតងាករេ ក្នុងការធានាការពារឱ្យបានដាច់ខាតនូវអធិបតេយ្យជាតិ និងបូរណភាពទឹកដី បានចាត់វិធានការបន្ទាន់ និងចាំបាច់នានាក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ទាំងទិដ្ឋភាពច្បាប់ បច្ចេកទេស និងនយោបាយការទូត ដើម្បី ទី១៖ ធានាកម្លាភាពចំពោះប្រជាជាតិទាំងមូល និងបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត អំពីភាពហ្មត់ចត់ ភាពត្រឹមត្រូវពិតប្រាកដ និងការទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំ និងការអនុវត្តការងាររបស់ខ្លួន ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជិតខាង។ ទី២៖ បញ្ចៀស និងបញ្ចប់នូវការញុះញង់ដោយគ្មានការទទួលខុសត្រូវ និងមិនក្រែងរអែងលើការបំពារបំពានច្បាប់ សំដៅបង្កើតស្មារតីជាតិនិយមជ្រុលធ្វើឱ្យមានការបែងបាក់ជាតិ និងបង្កើតភាពកាន់ច្រឡំនៅក្នុងចំណោមសាធារណៈមតិជាតិ និងអន្តរជាតិ ដើម្បីកេងចំណេញខាងនយោបាយ ដោយមជ្ឈដ្ឋានមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលជាប្រការអាចបង្កើតគ្រោះមហន្តរាយដ៏ធំធេងសម្រាប់ជាតិកម្ពុជាទាំងមូល ព្រមទាំងសម្រាប់សុខសន្តិភាពរវាងកម្ពុជា ជាមួយប្រទេសជិតខាងក្នុងតំបន់។ ទី៣៖ បញ្ជាក់ជាថ្មីម្តងហើយម្តងទៀត អំពីការប្តេជ្ញាចិត្តដ៏មោះមុតឥតងាករេរបស់

រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន សំដៅកសាងខ្សែបន្ទាត់ព្រំដែនមួយច្បាស់លាស់ ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍជាមួយប្រទេសជិតខាង។

ក្នុងស្មារតី និងគោលបំណងខាងលើ ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះផ្តល់នូវការបំភ្លឺដោយផ្ទាល់ជូនដល់បងប្អូនជនរួមជាតិគ្រប់រូប បន្ថែមទៅលើការបំភ្លឺទាំងឡាយដែលធ្លាប់បានធ្វើកន្លងមក ដោយផ្តោតលើចំណុច សំខាន់ៗមួយចំនួនដូចខាងក្រោម ៖

**I. អំពីសារៈសំខាន់នៃផែនទីព្រំដែនបច្ចុប្បន្នរវាងកម្ពុជា និងវៀតណាម៖**

ផែនទីផ្លូវការដែលរាជរដ្ឋាភិបាល កម្ពុជាបាននឹងកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែនជាមួយប្រទេសវៀតណាម គឺជាប្រភេទផែនទីបោន ខ្នាត១/១០០ពាន់ ដែលជាមរតកប្រវត្តិសាស្ត្រដែលអាណាព្យាបាលបារាំង និង**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** បានបន្សល់ទុកឱ្យ ពោលគឺផែនទីកំណត់ព្រំដែន ដោយផ្អែកតាមគោលការណ៍ខ្សែព្រំដែនមិនកែប្រែ នៅពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំង ហើយដែល**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះប្រមុខរដ្ឋនៅពេលនោះបានបញ្ជាក់ថា បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ និងបានស្នើសុំឱ្យប្រទេសមហាអំណាចទទួលស្គាល់នៅក្នុងឆ្នាំ១៩៦៤។ ផែនទីបោនខ្នាត១/១០០ពាន់នេះ គឺជាមូលដ្ឋានសំខាន់តែមួយគត់ ដែលត្រូវបានរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាយកមកប្រើប្រាស់ជាបន្តបន្ទាប់ នៅក្នុងការចុះកិច្ចព្រមព្រៀង និងសន្ធិសញ្ញាចំនួន៣ ដែលទាក់ទងទៅនឹងព្រំដែនគោកជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាមគឺ ៖

**១. សន្ធិសញ្ញាស្តីពីគោលការណ៍ដើម្បីដោះស្រាយព្រំដែន និងកិច្ចព្រមព្រៀងស្តីពីលក្ខន្តិកព្រំដែនរវាងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះកាលបរិច្ឆេទដូចគ្នា ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៣**

ផ្អែកតាមសន្ធិសញ្ញា និងកិច្ចព្រមព្រៀងខាងលើនេះ ភាគីទាំងសងខាងបានចាត់ទុកថា ព្រំដែនរដ្ឋរវាងកម្ពុជា និងវៀតណាម គឺជាព្រំដែនដែលមានរួចហើយ ដែលមានគូសលើផែនទីបោន ខ្នាត១/១០០ពាន់ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ដាក់ឱ្យប្រើប្រាស់មុនឆ្នាំ១៩៥៤ ឬនៅកាលបរិច្ឆេទកៀកបំផុតទៅនឹងឆ្នាំ១៩៥៤។ ការកំណត់យកផែនទីនេះ គឺស្របទៅនឹងគោលការណ៍ច្បាប់អន្តរជាតិស្តីពីខ្សែព្រំដែនមិនកែប្រែ ហើយវាស្របទៅនឹងផែនទីផ្លូវការដែលរាជរដ្ឋាភិបាលកម្ពុជា សម័យសង្គមរាស្ត្រនិយមនាពេលនោះបានប្រើប្រាស់ដើម្បីប្តឹងទៅអង្គការសហប្រជាជាតិ អំពីការរំលោភឈ្លានពានលើទឹកដីកម្ពុជាពីសំណាក់បរទេស។

**២. សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥៖**

សន្ធិសញ្ញានេះបានកំណត់យកគោលការណ៍ដូចក្នុងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ១៩៨៣ខាងលើ ដោយកំណត់យកផែនទីបោន ខ្នាត១/១០០ពាន់ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ដាក់ឱ្យប្រើប្រាស់មុនឆ្នាំ១៩៥៤ ឬកាលបរិច្ឆេទកៀកបំផុតទៅនឹងឆ្នាំ១៩៥៤ ដែលមាន២៦ផ្ទាំង អមដោយសន្ធិសញ្ញា និងផែនទី UTM ខ្នាត១/៥០ពាន់ ដែលគូសខ្សែព្រំដែនចេញពីផែនទីបោន ខ្នាត១/១០០ពាន់ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ធ្វើជាមូលដ្ឋានក្នុងការកំណត់ខ្សែព្រំដែនគោករវាងប្រទេសទាំងពីរ។ ការកំណត់យកផែនទីដោយសន្ធិសញ្ញានេះ គឺបន្តអនុវត្តដោយឥតងាករេ តាមគោលការណ៍ច្បាប់អន្តរជាតិស្តីពីខ្សែព្រំដែនមិនកែប្រែ និងតាមបណ្តាផែនទីដែលត្រូវបានប្រកាន់យកដោយ**សម្តេចព្រះនរោត្តម សីហនុ** ក្រោយពេលដែលកម្ពុជាបាន

ឯករាជ្យពីបារាំង។ ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះ ដើម្បីបញ្ជាក់ជូនបន្ថិចលើទិដ្ឋភាពខ្លះ មិនមែនជាការឆ្លើយតបសម្រាប់ពួកប្រឆាំងផ្កាប់មុខទេ គឺជាការបំភ្លឺចំពោះជនរួមជាតិ ដែលជាអ្នកស្នេហាជាតិពិតប្រាកដ ហើយដែលមិនមានការចង់បាននូវភាពចំណេញខាងនយោបាយណាមួយ។ តើហេតុអ្វីបានជាចាំបាច់ត្រូវមានផែនទី UTM ខ្នាត១/៥០ពាន់ អមជាមួយ។ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់អំពីចំណុចនេះបន្ថិចត្រង់ថា ផែនទីបោន ខ្នាត១/១០០ពាន់ ជាផែនទីមួយដែលពិបាករកឃើញចំណុចគោលនៃការបោះបង្គោលព្រំដែន ដូច្នេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការផ្ទេរព្រំដែនពីផែនទីបោន ខ្នាត១/១០០ពាន់ ចុះទៅផែនទី UTM ខ្នាត១/៥០ពាន់ ហើយនៅពេលខាងមុខ នៅពេលដែលយើងជួលក្រុមហ៊ុនដាណឺម៉ាកមួយ យើងអាចឈានទៅផ្ទេរផែនទីរហូតដល់ខ្នាត ១/២៥ពាន់ សម្រាប់តំបន់ខ្លះនៅក្នុងប្រទេសគឺយើងឈានទៅប្រើដល់ខ្នាត១/១០ពាន់។ ដូច្នេះត្រង់ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមជូននូវប្រការបីដែលទាក់ទងទៅនឹងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដើម្បីបញ្ជាក់ជូនជនរួមជាតិថាតើមានការប្រែប្រួលរវាងផែនទី UTM និងផែនទីបោនឬទេ? ប្រការបីនៃកិច្ចព្រមព្រៀងបំពេញបន្ថែមឆ្នាំ២០០៥នេះ បានបញ្ជាក់ច្បាស់ថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការងារបច្ចេកទេសសម្រាប់សម្រួលដល់ដំណើរការការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក គូភាគីសន្យាទាំងពីរបានឯកភាពគ្នា ៖ ១. ក្រុមជំនាញបច្ចេកទេសនៃភាគីនីមួយៗនឹងពិនិត្យនិងធ្វើការផ្ទៀងផ្ទាត់ជាឯកតោភាគីនៃការចម្លងឡើងវិញនៃខ្សែព្រំដែនពីផែនទីបោន ខ្នាត១/១០០ពាន់ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិនអមសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ១៩៨៥ មកលើផែនទី UTM ខ្នាត១/៥០ពាន់ អមសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ១៩៨៥ កថាខណ្ឌចុងក្រោយនៃចំនុចនេះបាននិយាយថា ចំពោះបណ្តាតំបន់ដែលភាគីគូសន្យាទាំងពីរ មិនទាន់ឯកភាពគ្នាទៅលើលទ្ធផលនៃការប្រៀបធៀប ឬទៅលើដំណោះស្រាយបច្ចេកទេសខ្សែព្រំដែនក្នុងតំបន់ទាំងនោះ និងគ្មានប្រែប្រួលអ្វីឡើយ ដូចបានកំណត់នៅលើផែនទីបោន ខ្នាត១/១០០ពាន់។ ចំណុចនេះគឺច្បាស់ណាស់ថា តំបន់មួយចំនួនដែលនៅមិនទាន់ដោះស្រាយបច្ចុប្បន្ន គឺជាការដែលយើងមិនទាន់ផ្ទេរផែនទីចេញពីផែនទីបោនទៅកាន់ផែនទី UTM បានច្បាស់លាស់ បានជាទីកន្លែងនោះមិនទាន់បានដោះស្រាយនៅឡើយ។

ឥឡូវនេះខាងមុខ ខ្ញុំព្រះករុណាខ្ញុំ នឹងនិយាយដល់មួយជំហានទៀត។ ថ្ងៃមុន ខ្ញុំព្រះករុណាខ្ញុំ បានជួបជាមួយបេសកជនពិសេសរបស់វៀតណាម ហើយបានលើកថា ប្រសិនបើភាគីទាំងពីរមិនឯកភាពគ្នាលើការផ្ទេរខ្សែផែនទី ពីផែនទីបោនទៅកាន់ផែនទី UTM ទេ យើងត្រូវសុំអ្នកបច្ចេកទេសបរទេស ឬជួលអ្នកបច្ចេកទេសបរទេសយកមក ដើម្បីផ្ទេរផែនទីនេះតែម្តង ដើម្បីធានានូវភាពត្រឹមត្រូវច្បាស់លាស់ទៅលើបញ្ហាទាក់ទិនជាមួយផែនទីដែលត្រូវផ្ទេរពីផែនទីបោន ខ្នាត១/១០០ពាន់ ទៅកាន់ផែនទី UTM ខ្នាត១/៥០ពាន់ផង និងដើម្បីធានាភាពត្រឹមត្រូវទៅលើការបោះបង្គោល តាមខ្សែបន្ទាត់ព្រំដែនផង។ ដោយសារតែនិយាយទៅដល់ប្រការនេះ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមបញ្ជាក់ថា នៅក្នុងកិច្ចព្រមព្រៀងបំពេញបន្ថែមនេះ ក៏មាននិយាយទៅដល់បញ្ហាចំណុចទី៥ដែលជាចំណុចចុងក្រោយនៃការព្រមព្រៀងនេះ ដើម្បីបង្កលក្ខណៈងាយស្រួល គឺបាននិយាយថា រហូតដល់ពេលដែលការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនមិនទាន់ត្រូវបានបញ្ចប់ទេ នោះការគ្រប់គ្រងខ្សែព្រំដែននឹងបន្តអនុវត្តតាមសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥ របស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ។ នៅក្នុងសេចក្តីប្រកាសនោះ ខ្ញុំព្រះករុណាខ្ញុំ សូមអានទៅនឹងសេចក្តីប្រកាសរបស់នាយករដ្ឋមន្ត្រីទាំងពីរ ដែលបាននិយាយច្បាស់នៅត្រង់ចំណុចភាគីទាំងពីរបញ្ជាក់សារជាថ្មីពី

ឆន្ទៈរបស់ខ្លួន ក្នុងការកសាងព្រំដែនរវាងប្រទេសទាំងពីរឱ្យក្លាយទៅជាព្រំដែនសន្តិភាព មិត្តភាព និងស្ថិរភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ និងភាពជាអ្នកជិតខាងល្អរវាងប្រទេសទាំងពីរ។ ដោយរង់ចាំដំណោះស្រាយលើបញ្ហាព្រំដែនដ៏សំខាន់នេះ ភាគីទាំងពីរឯកភាពរក្សាស្ថានភាពការគ្រប់គ្រងបច្ចុប្បន្ន ដោយមិនឱ្យមានការផ្លាស់ប្តូរ ឬរំកិលបង្គោលព្រំដែន និងអប់រំប្រជាជនដោយហាមប្រាមពួកគាត់មិនឱ្យធ្វើស្រែចំការ ឬតាំងទីលំនៅឆ្លងកាត់ព្រំដែន និងសហការគ្នារក្សាឱ្យបាននូវព្រំដែនសន្តិភាព និងសណ្តាប់ធ្នាប់។ ចំណុចនេះ គឺជាចំណុចដែលមានសារសំខាន់ សម្រាប់ការដោះស្រាយព្រំដែនរវាងយើងជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម។ យើងក៏ប្រើរូបមន្តដូចគ្នានេះជាមួយនឹងព្រំដែនជាមួយថៃ និងព្រំដែនជាមួយឡាវ អំពីការរក្សានូវស្ថានភាពនៅដដែល នៃការគ្រប់គ្រងបច្ចុប្បន្ននៅតំបន់ដែលមិនទាន់ដោះស្រាយ។ ត្រង់ចំណុចនេះដែរ ខ្ញុំព្រះករុណាខ្ញុំ ក៏គួរតែនិយាយ ព្រោះខ្ញុំព្រះករុណាខ្ញុំក៏នឹងបកស្រាយអំពីចំណុចដាក់ដាំ។ កិច្ចព្រមព្រៀងបំពេញបន្ថែមឆ្នាំ២០០៥ គឺមាននិយាយអំពីបញ្ហាទាក់ទិនជាមួយចំណុចចុងក្រោយអំពីកំណាត់ព្រំដែន តំបន់ជាប់នឹងឃុំដាក់ដាំ ស្រុកអូរាំង ខេត្តមណ្ឌលគិរី កម្ពុជា និងឃុំតាំជិត ស្រុកដាក់លិប ខេត្តដាក់ឡាក់ដាក់ណង វៀតណាម ភាគីគូសន្យាទាំងពីរបានឯកភាពគ្នាបន្តការពិភាក្សា។ ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ នឹងបញ្ជាក់នូវខាងក្រោមទៀត ដើម្បីបញ្ជាក់ឱ្យឃើញថា ការឈឺចាប់របស់ខ្ញុំព្រះករុណាខ្ញុំល្មមគ្រប់គ្រាន់ឱ្យខ្ញុំព្រះករុណាខ្ញុំធ្វើការបកស្រាយពន្យល់ឱ្យប្រជាពលរដ្ឋ ព្រះសង្ឃ និងប្រជាពលរដ្ឋយល់ឱ្យច្បាស់អំពីបញ្ហានេះថា ហេតុអ្វីបានជាខ្ញុំព្រះករុណាខ្ញុំត្រូវតស៊ូលើបញ្ហានេះ នៅពេលដែលរដ្ឋាភិបាលជំនាន់មុន តាំងពីឆ្នាំ១៩៦៤ បានបោះបង់ចោលរួចស្រេច តាមរយៈការបញ្ជូនផែនទីយកទៅកាន់អង្គការសហប្រជាជាតិ។ ការឈឺចាប់នេះ វាគ្រប់គ្រាន់ដើម្បីឱ្យខ្ញុំព្រះករុណាខ្ញុំធ្វើការបកស្រាយ បើទោះបីជាការបកស្រាយនោះវាមិនអនុគ្រោះសម្រាប់ប្រទេសជាតិ។ ខ្ញុំព្រះករុណាខ្ញុំ ចង់អនុគ្រោះ ចង់បានណាស់នូវអ្វីដែលជាផលប្រយោជន៍ជាតិ តាមភាពត្រឹមត្រូវដែលប្រវត្តិសាស្ត្របានបន្សល់ទុក ក៏ប៉ុន្តែពួកប្រឆាំង ពួកអគតិគេមានយោគយល់ចំពោះខ្ញុំព្រះករុណាខ្ញុំឬទេ? ក្រៅតែពីការជាន់ពន្លិចបន្ថែមនោះ។ ខ្ញុំព្រះករុណាខ្ញុំ សូមបន្ត បានបញ្ជាក់រួចហើយ ហើយក៏សូមបញ្ជាក់ថា មានអ្នកដែលបាននិយាយថា ផែនទីដែលបានរកឃើញនៅអាមេរិក គ្មានចុះហត្ថលេខាដោយវៀតណាម ឬដោយអ្នកណាទេ។ ច្បាស់ណាស់ ខ្ញុំព្រះករុណាខ្ញុំ ថ្ងៃនេះ យកផែនទី៤ផ្ទាំងយកមក មានផែនទីអមសន្ធិសញ្ញា មានផែនទីគណបក្សសង្គ្រោះជាតិ មានផែនទីបារាំងដែលទើបនឹងប្រគល់ និងមានផែនទីដែលអង្គការសហប្រជាជាតិបានផ្តល់ ដើម្បីយកមកធ្វើជាការបង្ហាញ។ ទោះបីថា ខ្ញុំព្រះករុណាខ្ញុំ មានផែនទីពីអាមេរិករួចស្រេចទៅហើយ ដែលអ្នកខ្លះទើបតែរកឃើញនូវប៉ុន្មានថ្ងៃមុននេះ ប៉ុន្តែខាងរាជរដ្ឋាភិបាលមានផែនទីនេះតាំងពីជាង១០ឆ្នាំមុននោះ។ ហេតុអ្វីបានជាផែនទីនេះត្រូវមានចុះហត្ថលេខាដោយមនុស្ស៤នាក់? សូមបញ្ជាក់ថា ផែនទីអមសន្ធិសញ្ញាចុះហត្ថលេខាផ្ទាំងនីមួយៗ ចុះហត្ថលេខាអមដោយមនុស្ស៤នាក់គឺ ៖ ប្រធានក្រុមបច្ចេកទេសផែនទីរបស់កម្ពុជា ដោយលោក **ឃាង យឿន** ប្រធានក្រុមបច្ចេកទេសផែនទីខាងវៀតណាម ដោយលោក **វ៉ូ ង៉ៀម** ប្រធានគណៈប្រតិភូរដ្ឋាភិបាលក្នុងគណៈកម្មាការចម្រុះរបស់កម្ពុជា ដោយឯកឧត្តម **ឌិត មន្ទី** បច្ចុប្បន្នជាប្រធានតុលាការកំពូល ប្រធានគណៈប្រតិភូខាងរដ្ឋាភិបាលវៀតណាមក្នុងគណៈកម្មការចម្រុះឈ្មោះ **លឺវ វ៉ាណ្ណលូវ**។ ហេតុអ្វីបានជាយើងចាំបាច់ត្រូវមានហត្ថលេខានៅលើផែនទីយ៉ាងដូច្នេះ? ព្រោះប្រហែលពេលបងប្អូនប្រជាពលរដ្ឋបានជ្រាបមករួចហើយថា មេបក្សនយោបាយមួយបាននិយាយថា ផែនទីអាចទិញតាមផ្សារ ឬវាអាចទិញតាមបណ្ណាល័យបាន។ បើផែនទីរកកន្លែងណាក៏បានដែរ ផែនទីនោះវា

ងាយណាស់នៅក្នុងការបន្លំ សូម្បីតែបណ្ណាកុងត្រានីមួយៗ ឬឯកសារជាអនុក្រឹត្យ ឬព្រះរាជក្រឹត្យ ឬច្បាប់ក៏សុទ្ធតែមានបោះត្រា និងការប្រថាប់ត្រាដោយមិនឱ្យមានការក្លែងបន្លំនៅក្នុងទំព័រណាមួយនោះទេ។ ដូច្នេះ ផែនទី២៦ផ្ទាំង បើសិនជាមិនមាននូវហត្ថលេខាទាំង២៦ផ្ទាំងទេ អ្នកដទៃអាចនឹងយកផែនទីមកដាក់ មិនថាភាគីកម្ពុជា ឬភាគីវៀតណាមនោះទេ។ នេះជាការភាន់ច្រឡំដ៏ធំ សូមបងប្អូនជនរួមជាតិមើលខ្លួនឯងទៅថា សូម្បីត្រឹមតែក្រដាសត្រឹមតែបីទំព័រក៏ត្រូវការហត្ថលេខាទាំងបីទំព័រផងដែរ ដើម្បីធានាសុក្រឹតភាពលើផ្លូវច្បាប់ ចុះទម្រាំទៅដល់ផែនទីរដ្ឋ។ វាត្រូវច្បាស់ណាស់ ផែនទីរដ្ឋត្រូវការទាំងការចុះហត្ថលេខាពីសំណាក់រាជរដ្ឋាភិបាល ពីសំណាក់ថ្នាក់ដឹកនាំរដ្ឋាភិបាល។ ផែនទីអមត្រូវចុះហត្ថលេខាដោយអ្នកបច្ចេកទេស ហើយត្រូវសុំការអនុម័តឱ្យសច្ចាប័នពីរដ្ឋសភា ពីនីតិបញ្ញត្តិ ហៅថាពីអង្គនីតិបញ្ញត្តិ ដែលប្រទេសខ្លះមានតែត្រឹមរដ្ឋសភា ត្រូវសុំរដ្ឋសភា ប្រទេសខ្លះមានរដ្ឋសភាផង និងព្រឹទ្ធសភាផងត្រូវសុំទាំងពីរ រួចហើយមានឡាយព្រះហស្ថលេខារបស់ព្រះមហាក្សត្រ។ សូមយល់ដឹងថា សូម្បីតែការកាត់ភូមិមួយឬកាត់ឃុំមួយ កំណត់ព្រំប្រទល់ឃុំ ឬកំណត់ព្រំប្រទល់ភូមិ ត្រូវចេញសេចក្ដីសម្រេចដោយអនុក្រឹត្យ បង្កើតស្រុក ព្រំប្រទល់ស្រុក ភូមិ ឃុំ ត្រូវកំណត់ដោយអនុក្រឹត្យ ព្រំប្រទល់ខេត្ត និងខេត្ត ត្រូវកំណត់ដោយព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ ព្រំប្រទល់រវាងរដ្ឋ និងរដ្ឋ ត្រូវឱ្យសច្ចាប័នយល់ព្រមពីសច្ចាប័នពីនីតិបញ្ញត្តិ និងឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ។ ត្រង់ចំណុចនេះ យើងត្រូវយល់ឱ្យច្បាស់ ដោយសារតែផែនទីដែលមានចុះហត្ថលេខាបែបនេះហើយ ទើបជាផែនទីដែលមិនអាចក្លែងបន្លំបាន ទោះក្នុងកាលៈទេសៈមានសង្គ្រាម ឬការមានកលិយុគ្គយ៉ាងណាក៏ដោយ ក៏សូមបងប្អូនជនរួមជាតិថា សូម្បីតែក្រដាសប្រាក់ចាយ ១០០ក្ដី ២០០ក្ដី ៥០រៀលក្ដី ក៏គង់មានចុះហត្ថលេខាដោយទេសាភិបាល និងបេឡាត្រឹមត្រូវ បើមិនដូច្នេះអ្នកគេអាចបោះពុម្ពក្រដាសប្រាក់យកទៅក្លែងក្លាយតាមទីផ្សារ។ ដូច្នេះ ខ្ញុំព្រះករុណាខ្ញុំ មានការចាំបាច់ដើម្បីពន្យល់ ថាហេតុអ្វីបានត្រូវមានចុះហត្ថលេខា តើការចុះហត្ថលេខានេះ វានាំទៅដល់ជាអាណានិគម ក្រោមអាណានិគមរបស់វៀតណាម ឬក៏ជាការស្មើភាព ឬស្មើសិទ្ធិ ជាមួយនឹងវៀតណាមនាដំណាក់កាលនោះ។ បើសិនតែមានចុះហត្ថលេខាដោយវៀតណាមម្នាក់ឯង នោះគឺច្បាស់ណាស់ថាកម្ពុជានឹងមិនអាចទទួលយកបានទេ។ ហើយបើសិនជាចុះហត្ថលេខាដោយកម្ពុជាតែឯង ក៏វៀតណាមមិនអាចទទួលយកបានដែរ ព្រោះយើងត្រូវធ្វើផែនទី ធ្វើព្រំដែនជាមួយនឹងប្រទេសជិតខាង។

**៣. សន្ធិសញ្ញាបំពេញបន្ថែមរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ទៅលើសន្ធិសញ្ញាទៅលើការកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥**

ផែនទីព្រំដែន ដែលប្រើក្នុងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥នេះ គឺជាប្រភេទផែនទីបោន ខ្នាត ១/១០០ពាន់ ដដែល ដូចក្នុងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ១៩៨៣ និងសន្ធិសញ្ញាព្រំដែនរដ្ឋឆ្នាំ១៩៨៥ ដែលបានរៀបរាប់ខាងលើ។ បន្ថែមលើនេះ តាមរយៈសន្ធិសញ្ញាបំពេញបន្ថែមនេះ កម្ពុជា និងវៀតណាមក៏បានឯកភាពគ្នាលើចំណុចសំខាន់ៗមួយចំនួនទៀត ទាក់ទងនឹងផែនទីសំដៅបង្កើតឱ្យបាននូវផែនទីព្រំដែនមួយស្អាត និងអចិន្ត្រៃយ៍ ដែលខ្ញុំព្រះករុណាខ្ញុំ ធ្លាប់បានផ្ដល់បំភ្លឺលំអិតរួចហើយ នៅក្នុងបទអន្តរាគមន៍រយៈពេលជាង៥ម៉ោង ជូនរដ្ឋសភាកាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២ កន្លងទៅ។ ហើយការបំភ្លឺនោះទៀតសោតក៏បានចាក់ផ្សាយតាមទូរទស្សន៍ និងក៏មានការបោះផ្សាយជាសៀវភៅនៃច្បាប់ដើមនេះ ដែលគេបាននៅតាមបណ្ណាល័យ ហើយប្រសិនបើមានការចាំបាច់ យើងនឹងចាក់ផ្សាយបន្តទៀតនូវគ្រប់ស្ថានីយ៍ទូរទស្សន៍

និងវិទ្យុដើម្បីការយល់ ប៉ុន្តែវាជាការលំបាកណាស់ នៅពេលដែលយើងផ្តុំខ្លួយឱ្យក្របីស្តាប់ ហើយយើងពិបាកខ្លាំងណាស់ គ្មាននរណាងងឹតជាងមនុស្សដែលមានភ្នែកភ្លឺ ហើយធ្វើជាខ្វាក់ និងគ្មាននរណាដែលថ្លង់ជាងមនុស្សដែលមានត្រចៀកល្អ តែមិនព្រមស្តាប់នោះទេ។ ជារួមសន្ធិសញ្ញា បំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីព្រំដែនអមសន្ធិសញ្ញានេះ គឺពិតជាមានអត្ថប្រយោជន៍ជាប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជា ក្នុងការកសាងព្រំដែនអចិន្ត្រៃយ៍មួយជាមួយប្រទេសវៀតណាម។ សន្ធិសញ្ញានេះមិនត្រឹមតែបញ្ជាក់ច្បាស់លាស់សារជាថ្មីអំពីការជ្រើសរើសរបស់កម្ពុជានូវគោលការណ៍ច្បាប់អន្តរជាតិ ដែលហៅថាគោលការណ៍ព្រំដែនមិនកែប្រែនៅពេលកម្ពុជាទទួលបានឯករាជ្យ ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែនកម្ពុជាជាមួយប្រទេសជិតខាងប៉ុណ្ណោះទេ ប៉ុន្តែសន្ធិសញ្ញានេះថែមទាំងបានជួសជុល កែលម្អ និងបំពេញបន្ថែម ទាំងខាងគោលការណ៍ច្បាប់ ទាំងខាងបច្ចេកទេស ទៅលើចំណុចខ្វះខាតទាំងឡាយនៃសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ទៀតផង។ ដូចនេះ សន្ធិសញ្ញាបំពេញបន្ថែមនេះបានបន្តកិច្ចការ ដែលមរតកប្រវត្តិសាស្ត្រនៃរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយមក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់**ព្រះបាទសម្តេចនរោត្តម សីហនុ** ដើម្បីនាំទៅរកការបញ្ចប់ទាំងស្រុងនូវខ្សែព្រំដែនមួយច្បាស់លាស់ ទាំងលើផែនទី ទាំងលើដីជាក់ស្តែង ដើម្បីធានាបាននូវបូរណភាពទឹកដីកម្ពុជា និងដើម្បីឱ្យប្រជាជនកម្ពុជាលែងមានការស្រពិចស្រពិល ស្គាល់ច្បាស់នូវព្រំដែនពិតប្រាកដរបស់ខ្លួន តាមរយៈ បង្គោលព្រំដែនដែលស្តែងឡើងនៅលើផែនទី ផែនដីជាក់ស្តែង លើដីជាក់ស្តែង ហើយងាយស្រួលក្នុងការចំណាំ ការគ្រប់គ្រង ការការពារ និងអភិវឌ្ឍ នៅតំបន់ព្រំដែន ព្រមទាំងនាំមកជូនភាគីទាំងសងខាងនូវទំនាក់ទំនងកាន់តែ ល្អប្រសើរ សុខសន្តិភាព និងភាពរីកចម្រើនរុងរឿង ទាំងខាងសង្គមកិច្ច សេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងការផ្លាស់ប្តូរទេសចរណ៍។ ចំណុចនេះ វាសំខាន់ណាស់សម្រាប់ប្រទេសរបស់យើង ព្រំដែននៅទិសខាងលិចវាងកម្ពុជា និងថៃបានប្រើប្រាស់ តាមរយៈនៃអនុស្សរណៈយោគយល់គ្នាឆ្នាំ២០០០ ដែលប្រើប្រាស់ខ្នាតផែនទី១/២០០ពាន់ ដែលគណៈកម្មាការបារាំងសៀមបានសម្រេច។ ជាមួយនឹងឡាវ យើងកំពុងដំណើរការទៅតាមកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ ដែលផ្អែកជាគោលនូវផែនទីខ្នាត១/១០០ពាន់។ ជាមួយវៀតណាមយើងកំពុងតែធ្វើនៅលើអ្វីដែល ខ្ញុំព្រះករុណាខ្ញុំបានបញ្ជាក់នៅក្នុងសន្ធិសញ្ញាឆ្នាំ១៩៨៣ ឆ្នាំ១៩៨៥ ហើយជាពិសេសបន្តមកឆ្នាំ២០០៥ ដែលខ្ញុំព្រះករុណាខ្ញុំបានបញ្ជាក់ជូនខាងលើអំបាញ់មិញ ទាក់ទងជាមួយនឹងការផ្ទេរខ្សែព្រំដែនពីព្រំដែនផែនទីបោនខ្នាត១/១០០ពាន់ ទៅផែនទី UTM ខ្នាត១/៥០ពាន់ ក្នុងករណីដែលផ្ទេរមិនបានត្រឹមត្រូវ មិនឯកភាពគ្នា ផែនទីបោននៅតែជាផែនទីផ្លូវការ ហើយក្នុងករណីខាងមុខគឺយើងនឹងពិភាក្សារកជំនាញការបរទេសមកតែម្តង ដើម្បីជួយផ្ទេរផែនទីពីផែនទីបោនទៅកាន់ផែនទី UTM ។ ក្រៅពីនោះ ការរក្សាស្ថានភាពដដែល និងការបន្តការចរចានៅតំបន់ដាក់ដាំ ដាក់ហ៊ុត ដែលខ្ញុំព្រះករុណាខ្ញុំ នឹងធ្វើអត្ថាធិប្បាយនៅពេលខាងមុខ។

### II. អំពីតម្លៃគតិយុត្តនៃផែនទីនៃព្រំដែនកម្ពុជា និងវៀតណាម

យោងតាមសាវតារដែលបានបញ្ជាក់ខាងលើ ផែនទីដែលរដ្ឋាភិបាលកម្ពុជាបានកំពុងតែប្រើប្រាស់ជាផ្លូវការក្នុងការកំណត់ និងការបោះបង្គោលព្រំដែនជាមួយនឹងប្រទេសវៀតណាម គឺមានលក្ខណៈសមស្របទាំងស្រុងទៅនឹងគតិនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺមាត្រា២ដែលចែងថា បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបំពានបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទី ខ្នាត១/១០០ពាន់ ធ្វើនៅចន្លោះឆ្នាំ១៩៣៣ ទៅឆ្នាំ១៩៥៣ ហើយដែលត្រូវទទួលស្គាល់ជាអន្តរជាតិ

នៅចន្លោះឆ្នាំ១៩៦៣ ទៅឆ្នាំ១៩៦៩។ លើសពីនេះទៀត តម្លៃគតិយុត្តនៃផែនទីព្រំដែននេះត្រូវបានពង្រឹងយ៉ាងរឹងមាំ ឥតរង្គោះរង្គើតាមរយៈច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ទៅលើសន្ធិសញ្ញាព្រំដែនរដ្ឋឆ្នាំ១៩៨៥ ដែលច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលជាតំណាងឱ្យឆន្ទៈនៃប្រជាជាតិខ្មែរអនុម័តយល់ព្រមកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៣។ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី១។ ស្របតាមនីតិវិធីជាធរមាន ច្បាប់នេះត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៥/០៣៩ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ បន្ទាប់ពីទទួលបានសេចក្តីក្រាបបង្គំទូលថ្វាយរួមគ្នា ពីសំណាក់សម្តេចជាស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងរូបខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ប្រការនេះគូសបញ្ជាក់ដោយមិនអាចប្រកែកបានថា សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥នេះត្រូវបានផ្តល់សច្ចាប័ន ដោយគោរពយ៉ាងត្រឹមត្រូវទៅនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ដូចនេះ គោលការណ៍ច្បាប់បន្ទាប់ពីផ្តល់សច្ចាប័នត្រឹមត្រូវស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិរួចមក សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីព្រំដែនដែលអមសន្ធិសញ្ញានេះ បានក្លាយជាឯកសារផ្លូវការតែមួយគត់ ដែលមានតម្លៃគតិយុត្តត្រឹមត្រូវតាមច្បាប់សម្រាប់ព្រះរាជាណាចក្រកម្ពុជា ធ្វើជាមូលដ្ឋានចរចាព្រំដែនជាមួយប្រទេសវៀតណាម។

ខ្ញុំព្រះករុណាខ្ញុំ សូមបង្ហាញជូននូវទិដ្ឋភាពច្បាប់ពាក់ព័ន្ធជាមួយនឹងកិច្ចព្រមព្រៀង ព្រមទាំងផែនទីនេះ។ នេះគឺជាព្រះរាជក្រម ដែលប្រកាសឱ្យប្រើច្បាប់ដែលទាក់ទងទៅនឹងសន្ធិសញ្ញាបំពេញបន្ថែម ដែលក្នុងនោះផែនទីដែលអមសន្ធិសញ្ញា គឺផែនទីស្របច្បាប់តែមួយគត់។ ការឡាយព្រះហស្តលេខារបស់ព្រះករុណាព្រះមហាក្សត្រ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ ហើយដែលពេលនោះមានការឡាយព្រះហស្តលេខា និងហត្ថលេខា រហូតនៅក្នុងនេះមានទៅដល់៤រូបឯណោះ ក្រៅពីប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៅមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រីម្នាក់ទៀតផង។ អញ្ចឹងទេនេះគឺជាទិដ្ឋភាពផ្លូវច្បាប់ ដែលមិនអាចបំពានបាន។ ខ្ញុំព្រះករុណាខ្ញុំ នឹងបញ្ជាក់ជូនថា បើទិដ្ឋភាពផ្លូវច្បាប់រឹងមាំប៉ុណ្ណឹងហើយ ហេតុអ្វីត្រូវការផែនទីយកមកផ្ទៀង ដើម្បីបញ្ជាក់បញ្ហានេះទៀត? មានផែនទីប៉ុណ្ណឹងហើយ ម្តេចមិនចាត់ការក្រុមនេះភ្លាមៗទៅ នៅពេលដែលគេធ្វើខុសច្បាប់? តើរាជរដ្ឋាភិបាលមានភាពទន់ភ្លន់ និងចង់បង្ហាញនូវអ្វីដែលជាផលប្រយោជន៍ជាតិដោយរបៀបណា? នោះហើយគឺជាការចង់បានរបស់រាជរដ្ឋាភិបាលទៅលើបញ្ហាឯកភាពជាតិ ហើយឯកភាពជាតិដំបូងគឺចាប់ផ្តើមពីការប្រើប្រាស់ផែនទី។

មួយវិញទៀត សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ គឺជាកិច្ចព្រមព្រៀងទ្វេភាគីដែលមានតម្លៃគតិយុត្តស្របតាមច្បាប់អន្តរជាតិ ជាពិសេស អនុសញ្ញាទីក្រុងវីយែនស្តីពីនីតិសន្ធិសញ្ញាដែលព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម គឺជាភាគីហត្ថលេខី បន្ទាប់ពីសន្ធិសញ្ញានេះត្រូវបានផ្តល់សច្ចាប័នស្របតាមផ្ទៃក្នុងនៃរដ្ឋភាគីរៀងៗខ្លួន និងបន្ទាប់ពីបានធ្វើការផ្លាស់ប្តូរលិខិតូបករណ៍សច្ចាប័នរវាងគ្នា និងគ្នារួចហើយ។ សន្ធិសញ្ញានេះបានចូលជាធរមាន និងមានអនុភាពអនុវត្តស្របតាមច្បាប់នៃប្រទេសនីមួយៗ និង

ស្របតាមច្បាប់អន្តរជាតិសម្រាប់ភាគីទាំងពីរ។ ដូចនេះ សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីអមសន្ធិសញ្ញានេះក៏ជាឯកសារផ្លូវការជាមូលដ្ឋានដែលមានតម្លៃគតិយុត្តស្របតាមច្បាប់អន្តរជាតិផងដែរ សម្រាប់ជាមូលដ្ឋានក្នុងការចរចា និងកំណត់ព្រំដែនរដ្ឋរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ថា យោងទៅលើទិដ្ឋភាពទាំងឡាយក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ នៅពេលដែលមានកិច្ចព្រមព្រៀងដែលតម្រូវឱ្យមានការសុំសច្ចាប័នពីរដ្ឋសភា។ នៅកម្ពុជាមានកិច្ចព្រមព្រៀងខ្លះមិនតម្រូវឱ្យមានការសុំសច្ចាប័នពីរដ្ឋសភានោះទេ ប៉ុន្តែចំពោះកិច្ចព្រមព្រៀងព្រំដែន ជាទូទៅមិនថាប្រទេសកម្ពុជា ឬប្រទេសណានោះទេ គឺតម្រូវឱ្យមានការសុំសច្ចាប័នពីអង្គការនីតិបញ្ញត្តិ។ បើសិនជាប្រទេសណាមួយមិនឱ្យសច្ចាប័ន គឺមានន័យថារាជរដ្ឋាភិបាល និងរដ្ឋាភិបាលដែលទៅចុះហត្ថលេខានេះអនុវត្តមិនបានទេ។ នៅពេលឱ្យសច្ចាប័នរួចហើយ ភាគីទាំងពីរត្រូវប្តូរសារគ្នាទៅវិញទៅមក ដែលគេហៅថាការប្តូរលិខិតុបករណ៍ ដើម្បីឱ្យក្លាយទៅជាផ្លូវច្បាប់ និងមានការឯកភាព។ ហេតុអ្វីបានជាត្រូវមានការធ្វើយ៉ាងនេះ? កុំថាឡើយរវាងរដ្ឋ និងរដ្ឋ សូម្បីតែព្រំដីរបស់យើងជាមួយព្រំដីអ្នកជិតខាង ក៏ត្រូវការការឯកភាពគ្នាថា តើត្រូវធ្វើរបងរបៀបណា បើសិនជាខ្ញុំធ្វើរបងបំពានទៅលើដីអ្នកដទៃ ឬអ្នកដទៃធ្វើរបងបំពានមកលើដីខ្ញុំ គឺច្បាស់ជាមានជម្លោះរវាងគ្រួសារទាំងពីរដែលរស់នៅជិតខាងគ្នា។ សូមកុំនិយាយឡើយរវាងរដ្ឋ និងរដ្ឋ ដែលទាំងសងខាងសុទ្ធតែមានកងទ័ពកងកម្លាំងប្រដាប់អាវុធ ទាំងយើងជាមួយឡាវ ទាំងយើងជាមួយវៀតណាម ទាំងយើងជាមួយថៃ ទាំងថៃជាមួយឡាវ ទាំងថៃជាមួយមីយ៉ាន់ម៉ា និងថៃជាមួយកម្ពុជា វៀតណាមជាមួយឡាវ វៀតណាមជាមួយកម្ពុជា វៀតណាមជាមួយចិន គឺសុទ្ធតែមានការឯកភាពគ្នាទាំងអស់។ ដូចនេះ ព្រំដែនរបស់យើង ផែនទីដែលយើងប្រើប្រាស់ មិនមែនជាផែនទីដែលយើងដាក់ចេញជាឯកតោភាគី ហើយដាក់ឱ្យភាគីម្ខាងទៀតត្រូវតែទទួលយក ហើយយើងក៏មិនអាចទទួលយកនូវផែនទីដែលប្រទេសដទៃនៅជាប់ជិតខាងយើង តម្រូវឱ្យយើងយកនោះដែរ។ ដូចនេះ បានជាយើងជាមួយថៃ យើងជាមួយឡាវ យើងជាមួយវៀតណាម ចាំបាច់ត្រូវការឱ្យមានការឯកភាពគ្នាទៅលើការប្រើប្រាស់ផែនទី។ ដូចនេះ ផែនទីរបស់យើងនេះតម្រូវក្នុងទិដ្ឋភាពច្បាប់ បានបំពេញគ្រប់គ្រាន់តាមផ្លូវផ្ទៃក្នុងរបស់ខ្លួនឯងផង និងតាមផ្លូវច្បាប់អន្តរជាតិផងដែរ។

ផ្អែកលើគ្រប់ទិដ្ឋភាពខាងលើនេះ ផែនទីព្រំដែនដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែនជាមួយប្រទេសវៀតណាមនេះ គឺជាផែនទីផ្លូវការតែមួយគត់ដែលមានតម្លៃគតិយុត្តពេញលេញ ទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់អន្តរជាតិ ដើម្បីប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងការកំណត់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ បន្ថែមពីលើនេះទៀត នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ ដែលជាថ្ងៃឡាយព្រះហស្ថលេខាលើព្រះរាជក្រម ប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋក្នុងឆ្នាំ១៩៨៥ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានចេញព្រះរាជសារជូនជនរួមជាតិខ្មែរទាំងមូល ដែលមានខ្លឹមសារគួសបញ្ជាក់បន្ថែមទៀតថា គ្រប់ស្ថាប័នជាតិកំពូលរបស់ព្រះរាជាណាចក្រកម្ពុជា រួមមានរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលកម្ពុជា ដែលជាតំណាងឱ្យឆន្ទៈនៃជនជាតិខ្មែរទាំងមូលស្របតាមគោលការណ៍នៅក្នុងសង្គមប្រជាធិបតេយ្យ និងជាស្ថាប័នដែលទទួលខុសត្រូវលើជោគវាសនាប្រទេសជាតិ បានពិនិត្យឃើញយ៉ាងច្បាស់ និងបានធានាអះអាងថា ផែនទីព្រំដែនកម្ពុជា និងវៀតណាម អមដោយ

សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ គឺជាផែនទីមានភាពត្រឹមត្រូវ មិនធ្វើឱ្យបាត់បង់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជានោះឡើយ។

ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមបង្ហាញប្រគេនជូនព្រះសង្ឃគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិ នេះជាព្រះរាជសាររបស់ព្រះមហាក្សត្រ ដែលព្រះអង្គបានផ្ញើប្រគេនជូនព្រះសង្ឃ និងជនរួមជាតិនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ ដែលជាថ្ងៃដែលព្រះអង្គបានឡាយព្រះហស្ថលេខាលើព្រះរាជក្រម ដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការឱ្យសច្ចាប័នលើសន្ធិសញ្ញាបំពេញបន្ថែម ដែលក្នុងនោះមានអមដោយផែនទីទៀតផង។ នៅក្នុងចំណុចនេះ ក្រៅពីការអះអាងពីសំណាក់រាជរដ្ឋាភិបាល ពីសំណាក់រដ្ឋសភា ព្រឹទ្ធសភា ព្រះករុណាព្រះអង្គម្ចាស់ព្រះអង្គក៏បានពិគ្រោះយោបល់ជាមួយនឹងរាជវង្សានុវង្ស ដែលមានសម្តេចព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស** ដែលពេលនោះជាអនុប្រធានទីមួយនៃព្រឹទ្ធសភា **សម្តេចនរោត្តម សេរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសម្តេចព្រះ**មហេសាក់ នរោត្តម ចក្រពង្ស** ដែលពេលនោះជាទីប្រឹក្សារាជរដ្ឋាភិបាល ក៏បានថ្វាយនូវព្រះរាជយោបល់ថា ជាការទទួលខុសត្រូវរបស់អង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ។ ដូចនេះ នេះជាការយកព្រះទ័យទុកដាក់លើបញ្ហានេះ។

ក្រៅពីការឡាយព្រះហស្ថព្រមគ្នាលើព្រះរាជក្រមដាក់ឱ្យប្រើប្រាស់នូវច្បាប់នេះ ព្រះអង្គក៏បានដាក់ចេញនូវព្រះរាជសារជូនព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិផងដែរ ហើយដែលកន្លងទៅវិទ្យុ និងទូរទស្សន៍បានផ្សាយជាហូរហែរផងដែរ និងសង្ឃឹមថាបណ្តាទូរទស្សន៍នានានឹងបន្តចាក់ផ្សាយនូវព្រះរាជសាររបស់ព្រះករុណាព្រះមហាក្សត្របច្ចុប្បន្ន ក៏ដូចជាព្រះរាជសាររបស់ព្រះករុណាអតីតព្រះមហាក្សត្រ **សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ផ្ញើជូនឯកឧត្តម **ផាន់ វ៉ាន់ដុង** នៅក្នុងឆ្នាំ១៩៩៩ ស្តីអំពីព្រំដែនទឹកដោយយក Ligne Brevier និងព្រះរាជក្រមប្រកាសឱ្យច្បាប់នេះផងដែរដើម្បីផ្សព្វផ្សាយជូនជនរួមជាតិ ដើម្បីជៀសវាងការធ្វើអត្ថាធិប្បាយ និងការញុះញង់បង្កហេតុពីសំណាក់ពួកមិនទទួលខុសត្រូវ ហើយដែលព្យាយាមធ្វើឱ្យសភាពការណ៍អាប់អួរ ឬបង្កើតជាចលាចល។

### III. អំពីភាពត្រឹមត្រូវនៃផែនទីព្រំដែនកម្ពុជា និងវៀតណាម

ផ្អែកលើសារតារ និងគតិច្បាប់ដូចបានរំលេចខាងលើ ផែនទីព្រំដែនអមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ គឺជាផែនទីផ្លូវការតែមួយគត់ដែលមានតម្លៃគតិយុត្តពេញលេញស្របតាមច្បាប់ជាតិ និងអន្តរជាតិសម្រាប់ការចរចា និងកំណត់ព្រំដែនរដ្ឋរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ដូចនេះ តាមផ្លូវច្បាប់វាពិតជាមិនមានការចាំបាច់ណាមួយ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការស្វះស្វែងរកកិច្ចសហប្រតិបត្តិការស្នើសុំខ្ចីផែនទី ដើម្បីផ្ទៀងផ្ទាត់ជាមួយផែនទីផ្លូវការ និងស្របច្បាប់ដែលរាជរដ្ឋាភិបាលបាននឹងកំពុងប្រើប្រាស់ក្នុងការចរចាព្រំដែន និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាមនោះឡើយ។ នេះជាចំណុច ដែលខ្ញុំព្រះករុណាខ្ញុំ បានលើកឡើងពីខាងលើនេះថា ផែនទីផ្លូវច្បាប់បែបនេះហើយ ទៅរកខ្ចីគេមកធ្វើអ្វី? ហើយចំណុចនេះគឺចម្លើយនៅទីនេះ និងផ្នែកខាងក្រោម។ ខ្ញុំព្រះករុណាខ្ញុំ ក៏បានប្រាប់ទៅឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិថា សូមឯកឧត្តមកុំបន្ទោសខ្ញុំដែលខ្ញុំបានរកវិធីឱ្យសត្វមានពិសចេញពីរូង ព្រោះផែនទីឯកឧត្តមសាហាវជាងសត្វអសិរពិសទៅទៀត ព្រោះមិនត្រឹមតែបោកប្រាស់ប្រជាពលរដ្ឋនោះទេ គឺបានធ្វើឱ្យសហការីរបស់គាត់ជាប់គុកមកទល់ពេលនេះ ហើយអាចនឹងមានជាប់គុកជាបន្តបន្ទាប់ទៀត។ ការជាប់គុកនេះ គឺអាស្រ័យទៅលើតុលាការនោះទេ ប៉ុន្តែនៅពេលនេះគឺនៅជាប់ឃុំនៅឡើយនោះទេ។ ទោះបីយ៉ាង

នេះក្ដី គណបក្សប្រឆាំងតំណាងដោយអ្នកនយោបាយមួយចំនួនរបស់ខ្លួន នៅតែបន្ដធ្វើជាមិនយល់នូវតម្លៃគតិយុត្ត និងអត្ថប្រយោជន៍នៃសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីអមសន្ធិសញ្ញា ហើយបែរជាធ្វើការចោទប្រកាន់ ដោយមិនញញើតបន្ដិចណាឡើយចំពោះច្បាប់មានជាធរមាន និងបានប្រមាថមាក់ងាយដោយឥតកោតក្រែងទៅលើស្ថាប័នកំពូលទាំងឡាយរបស់ជាតិ រួមទាំងព្រះមហាក្សត្រ ផងថាផែនទីព្រំដែនផ្លូវការ និងស្របច្បាប់នេះ ជាផែនទីក្លែងក្លាយ ឬជាផែនទីមិនត្រឹមត្រូវ ឬជាផែនទីចោរថែមទៀតផង។ ឥឡូវនៅទីនេះ តើទាំងបួនតួអង្គនេះជាចោរ ឬយ៉ាងណា? នេះជាការប្រមាថដែលមិនត្រូវលើកលែង។ **ព្រះមហាក្សត្រព្រះនាមសីហមុនី** ប្រធានព្រឹទ្ធសភាដែលទទួលមរណភាពទៅហើយ **សម្ដេច ជា ស៊ីម** ប្រធានរដ្ឋសភា**ព្រះនាមសម្ដេចនរោត្ដម រណឫទ្ធិ** និងនាយករដ្ឋមន្ត្រីខ្ញុំព្រះករុណាខ្ញុំ **ហ៊ុន សែន**។ តើនេះ អ្នកដែលប្រមាថផែនទីថា ជាផែនទីចោរ មិនត្រឹមត្រូវ ក្លែងក្លាយ តើមានបានគិតទៅដល់ស្ថាប័នកំពូលរបស់ជាតិទេ? ខ្ញុំព្រះករុណាខ្ញុំជានាយករដ្ឋមន្ត្រី **សម្ដេចក្រុមព្រះរណឫទ្ធិ** ជាប្រធានរដ្ឋសភា **សម្ដេច ជា ស៊ីម** ជាប្រធានព្រឹទ្ធសភា និង**សម្ដេចព្រះបរមនាថនរោត្ដម សីហមុនី** ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ តើការបំពានបែបនេះត្រូវទទួលទោសបែបណា? ស្នើឱ្យអង្គអ្នកច្បាប់ និងវិស័យតុលាការសិក្សាឱ្យបានច្បាស់លាស់ ដើម្បីចាត់វិធានការណ៍ចំពោះជនទាំងឡាយណាហ៊ានប្រមាថទៅលើផែនទីដែលកំពុងប្រើប្រាស់ជាផ្លូវការនៅពេលនេះ។

ដូចនេះ ដើម្បីជានាតម្លាភាពសម្រាប់ប្រជាជាតិកម្ពុជាទាំងមូល ក៏ដូចជាការបញ្ជាក់ឱ្យកាន់តែច្បាស់បន្ថែមទៀតអំពីភាពហ្មត់ចត់ត្រឹមត្រូវ និងការទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំ និងការអនុវត្តការងាររបស់ខ្លួន ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនរវាងប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង។ រាជរដ្ឋាភិបាលកម្ពុជាបានស្វះស្វែងរកកិច្ចសហការស្នើសុំខ្ចីផែនទីដែលមានការពាក់ព័ន្ធពីអង្គការសហប្រជាជាតិនិងពីប្រទេសមហាអំណាចចំនួន៣គឺ ៖ សាធារណរដ្ឋបារាំង សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ដើម្បីផ្ទៀងផ្ទាត់ជាមួយផែនទីផ្លូវការ និងស្របច្បាប់ដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។ ដូចបានគូសបញ្ជាក់ពីខាងដើម ការស្នើសុំខ្ចីផែនទីនេះក៏ធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ចៀស និងបញ្ចប់នូវការញុះញង់ដោយគ្មានការទទួលខុសត្រូវ និងមិនខ្លាចញញើតច្បាប់រដ្ឋ សំដៅបង្កើតស្មារតីជាតិនិយមជ្រុល ធ្វើឱ្យមានការបែកបាក់ជាតិ និងបង្កើតឱ្យមានការភាន់ច្រឡំនៅក្នុងសាធារណៈមតិជាតិ និងអន្តរជាតិ ដើម្បីកេងចំណេញនយោបាយដោយមជ្ឈដ្ឋានមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលជាប្រការអាចបង្កើតគ្រោះមហន្តរាយដ៏ធំធេងសម្រាប់កម្ពុជាទាំងមូល ព្រមទាំងសម្រាប់សន្តិសុខជាមួយប្រទេសជិតខាង និងក៏ដើម្បីបញ្ជាក់ពីការតាំងចិត្តឥតងាករេរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន សំដៅកសាងខ្សែព្រំដែនមួយត្រឹមត្រូវ ច្បាស់លាស់ ប្រកបដោយសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍជាមួយប្រទេសជិតខាង។ អ្វីដែលរាជរដ្ឋាភិបាលចង់បាន គឺតម្លាភាពជាមួយប្រជាជាតិកម្ពុជាទាំងមូល ក៏ប៉ុន្តែ ខ្ញុំព្រះករុណាខ្ញុំ ក៏ចង់ឱ្យសត្វមានពិសចេញពីរូង ដែលវាសាហាវជាងសត្វអសិរពិស ព្រោះគេគ្រាន់តែបង្ហោះតាមហ្វេសប៊ុក (Facebook) ហើយគេបង្កើតនូវការញុះញង់ បោកបញ្ឆោតប្រជាពលរដ្ឋ តើគេគួរទទួលខុសត្រូវចំពោះមុខច្បាប់ដោយរបៀបណា ប្រសិនបើមានយថាហេតុអាក្រក់កើតឡើង ដូចជាការកាប់សម្លាប់គ្នានៅក្នុងផ្ទៃក្នុងជាតិ ឬការប៉ះទង្គិចតាមទល់ដែន តាមរយៈការញុះញង់របស់មេដឹកនាំ។ យ៉ាងហោចណាស់ គេក៏ត្រូវទទួលខុសត្រូវខាងសីលធម៌ផងដែរ នៅពេលដែលគេធ្វើការញុះញង់បំបែកបំបាក់ជាតិ តាមរយៈការប្រើប្រាស់ផែនទី យកមកបង្ហោះតាម

របៀបសត្វមានពិស ហើយវាសាហាវជាងសត្វអសិរពិស។ តាមរយៈនៃការស្នើសុំរបស់ខ្ញុំព្រះករុណាខ្ញុំ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ បានធ្វើលិខិតមួយច្បាប់ជូនទៅឯកឧត្តម **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសុំខ្ចីផែនទីទាំងអស់ដែលតម្កល់នៅអង្គការសហប្រជាជាតិ។ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥ ឯកឧត្តម **បាន គីមូន** បានធ្វើលិខិតឆ្លើយតបមកវិញដោយបញ្ជាក់ថា ពុំអាចរកឃើញផែនទីបោន ខ្នាត១/១០០ពាន់ ដែលរាជរដ្ឋាភិបាល**សម្តេចនរោត្តម សីហនុ** បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៦៤នោះទេ។ ប៉ុន្តែ បានរកឃើញនូវផែនទី១៨ផ្ទាំង ដែលតម្កល់នៅបណ្ណាល័យហាម៉ាស៊ុល របស់អង្គការសហប្រជាជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជាសម័យសង្គមរាស្ត្រនិយមក្រោមព្រះរាជកិច្ចដឹកនាំរបស់**សម្តេចនរោត្តម សហីនុ** ព្រះប្រមុខរដ្ឋបានប្រើប្រាស់ផែនទីនោះប្តឹងទៅអង្គការសហប្រជាជាតិអំពីការរំលោភឈ្លានពានកម្ពុជាពីសំណាក់បរទេស។ អង្គការសហប្រជាជាតិអនុញ្ញាតឱ្យប្រទេសកម្ពុជាខ្ចីផែនទី១៨ផ្ទាំងនេះ ជាការយោគយល់ពិសេស។ ខ្ញុំព្រះករុណាខ្ញុំសូមបំភ្លឺនូវចំណុចនេះបន្តិច។ អង្គការសហប្រជាជាតិ តាមរយៈលិខិតរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ **បាន គីមូន** គ្រាន់តែបានបញ្ជាក់មកខ្ញុំព្រះករុណាខ្ញុំថាផែនទីនេះរកមិនឃើញ តែមិនបានបញ្ជាក់ប្រាប់ថាបានយកទៅតម្កល់ ឬមិនយកទៅតម្កល់នោះទេ។ ដូចនេះ ក្នុងឋានៈជាក្មេងជំនាន់ក្រោយ ខ្ញុំព្រះករុណាខ្ញុំមិនអាចដឹងបានថា តើពេលនោះរាជរដ្ឋាភិបាលកម្ពុជាបានយកទៅតម្កល់មែន ឬអត់ ឬយកទៅតម្កល់ តែអង្គការសហប្រជាជាតិធ្វើឱ្យបាត់ ឬមិនបានយកទៅតម្កល់។ ដូចនេះហើយបានជាខ្ញុំព្រះករុណាខ្ញុំ ស្នើសុំឱ្យនៅតែបន្តការស្វះស្វែងរកបន្តទៀត។ ខ្ញុំព្រះករុណាខ្ញុំ មិនយកការសន្និដ្ឋានណាមួយនៅពេលនេះថា នៅពេលនោះបានយកទៅតម្កល់ ឬក៏អត់។ ឯអគ្គលេខាធិការអង្គការសហប្រជាជាតិក៏មិនបានបញ្ជាក់នៅក្នុងលិខិតរបស់ខ្លួនថា មិនបានយកទៅតម្កល់ទេ គ្រាន់តែថារកមិនឃើញតែប៉ុណ្ណោះ។ ប៉ុន្តែ គេបែរជារកឃើញនូវផែនទីដែលកម្ពុជាបានប្តឹងទៅអង្គការសហប្រជាជាតិស្តីអំពីការឈ្លានពានរបស់អាមេរិក និងវៀតណាមខាងត្បូងកាលពីពេលនោះទៅវិញ។ ផែនទីនោះយើងអាចចាត់ទុកថាជាផ្នែកមួយនៃព្រំដែនកម្ពុជាផងដែរ ព្រោះពេលដែលយើងបានដាក់ផែនទីទៅ នៅទីតាំងទម្លាក់គ្រាប់បែកទាំងឡាយ មានន័យថាយើងបានកំណត់ថានេះជាដីខ្មែរ នេះជាដីវៀតណាម តាមរយៈផែនទីដែលយើងបានដាក់ទៅ។ ទោះបីយើងមិនបានដាក់ទៅតម្កល់ថានេះជាផែនទីព្រំដែន។ ប៉ុន្តែ ផែនទីទាំង១៨ផ្ទាំងនេះល្មមគ្រប់គ្រាន់ដែលអាចឱ្យយើងយល់ថា ពេលនោះព្រំដែនរបស់យើងប៉ុណ្ណឹងឯង។ យើងក៏សុខចិត្តខ្ចីមក ហើយតាមលក្ខណៈយោគយល់ ដែលយើងបានថ្លែងអំណរគុណចំពោះអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ខ្ញុំព្រះករុណាខ្ញុំ សូមទម្លាយរឿងនេះដើម្បីជ្រាប។ នេះជាតំបន់ដែលមានការពាក់ព័ន្ធនឹងមាត្រាដែលពាក់ព័ន្ធជាមួយ នឹងការបន្តការចរចារវាងកម្ពុជា និងវៀតណាមនៅតំបន់ដាក់ដាំ និងដាក់ហ៊ូត។ តាមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥។ ចំណុចខ្សែព្រំដែននេះ សូមបញ្ជាក់ថាអគ្គទេសាភិបាលឥណ្ឌូចិនឆ្នាំ១៩១៤ បានកំណត់ឱ្យខ្សែព្រំដែនដើរមកតាមព្រែកដាក់ហ៊ូត។ ប៉ុន្តែបារាំងបានគូសផែនទីមកតាមព្រែកដាក់ដាំ ដែលខុសផ្ទៃដីចំនួនប្រមាណជា៥០គីឡូម៉ែត្រក្រឡា។ ខ្ញុំព្រះករុណាខ្ញុំបានប្រឹងប្រែងណាស់ ដើម្បីតស៊ូដោះស្រាយបញ្ហានេះ ដោយស្នើឱ្យភាគីវៀតណាមទទួលយកនូវការគូសផែនទីឱ្យត្រឹមត្រូវទៅតាមការកំណត់នៃអគ្គទេសាភិបាលឥណ្ឌូចិនឆ្នាំនោះ។ ពេលនោះខ្សែខៀវនេះ ជាខ្សែដែលខ្ញុំព្រះករុណាខ្ញុំបានគូសកាលពីព្រឹកមិញ ដើម្បីងាយពន្យល់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។ ប៉ុន្តែខ្សែព្រំដែនដែលយើងបានប្រគល់ឱ្យអង្គការសហប្រជាជាតិ គឺខ្សែរត់តាមព្រែកដាក់ដាំ ហើយដែលតាំងពីពេលការគូស

ផែនទីខុសមកទល់ពេលនេះ យើងមិនទាន់ស្វែងរកនូវឯកសារណាមួយដែលកម្ពុជាបានទាមទារឱ្យបារាំងគូសឡើងវិញនោះទេ ទោះបារាំងបានគូសផែនទីខុសពីការកំណត់របស់អគ្គទេសាភិបាលឥណ្ឌូចិន។ កម្ពុជាមិនបានតស៊ូទាមទារឱ្យបារាំងកែប្រែនូវការគូសខុសផែនទីនេះទេ។ ផ្ទុយទៅវិញ បានប្រើប្រាស់ផែនទីនេះហើយយកផែនទីនេះទៅប្តឹងគេនៅអង្គការសហប្រជាជាតិ។ នេះជាចំណុចនៃការទម្លាក់គ្រាប់បែករបស់អាមេរិកកាលពីឆ្នាំ១៩៦៤។ នេះជាចំនុចមួយ នេះជាចំនុចមួយ ហើយយើងយកផែនទីទៅដាក់ឱ្យគេយ៉ាងដូច្នេះ។ រង្វង់ផ្ទៃដីនេះជារង្វង់ដែលយើងកំពុងតស៊ូ សូមឱ្យវៀតណាមទទួលយកនូវការកំណត់តាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន។ ជាការគួរឱ្យចង់សើចដែលមេដឹកនាំនយោបាយមួយរូបជាប្រធានបក្សនយោបាយនិយាយថា ផែនទីឆ្នាំ១៩១៤។ សូមប្រជាពលរដ្ឋយល់ឱ្យច្បាស់ បើធ្វើជាមេដឹកនាំរហូតដល់ល្ងង់ខ្លៅដែលមិនដឹងថាអ្វីជាសេចក្តីសម្រេច និងអ្វីជាផែនទីផងនោះ តើសមស្របធ្វើជាមេដឹកនាំកម្ពុជាបានដែរឬទេ ប្រជាពលរដ្ឋត្រូវយល់ឱ្យច្បាស់ថា តើគួរបោះឆ្នោតឱ្យគាត់ដឹកនាំប្រទេសដែរឬអត់? ប្រមាណអាទិត្យនេះគាត់ថាត្រូវទាមទារឱ្យប្រើផែនទីឆ្នាំ១៩១៤ ខ្ញុំព្រះករុណាខ្ញុំសូមបញ្ជាក់ជូនទៅកាន់បងប្អូនជនរួមជាតិ ក៏ដូចជាទៅកាន់សមាជិកសមាជិកាគណបក្សប្រឆាំងឱ្យបានជ្រាបថា មេបក្សរបស់ខ្លួននេះល្ងង់ដល់ប៉ុណ្ណឹង តើអាចដឹកនាំជាតិបានឬទេ? ខ្លួនសមស្របជាមេដឹកនាំរបស់ខ្លួនបន្តទៀតទេ បើសូម្បីតែសេចក្តីសម្រេច និងផែនទី គឺខ្លួនអត់ច្បាស់ផង។ សេចក្តីសម្រេច គឺគេឱ្យដើរតាមព្រែក ដាក់ហ៊ូតរហូតទៅដល់ប្រភពរបស់វា ប៉ុន្តែផែនទីគេគូសតាមព្រែកដាក់ដាំ អញ្ចឹងផែនទីដែលគូសតាមដាក់ហ៊ូត អត់មានផែនទីទេ មានតែសេចក្តីសម្រេចតែប៉ុណ្ណោះ។ ឥឡូវដើម្បីជម្រះមន្ទិលតែម្តង ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ជូនជនរួមជាតិ នេះជាការលះបង់តាំងពីឆ្នាំ១៩៦៤ ដែលពេលនោះឧត្តមសេនីយ លោក **កែវ ផាត** បានយកទៅប្តឹងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៦៤ ហើយការយកទៅប្តឹងគេ យកទៅផែនទីយ៉ាងដូច្នេះ មិនបានស្នើសុំបារាំងឱ្យកែផែនទីទេ មិនបានទាមទារឱ្យខ្សែផែនទីដើរស្របទៅតាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិនទេ ប៉ុន្តែបែរជាយកផែនទីទៅប្តឹងគេនៅអង្គការសហប្រជាតិ ដែលជាផ្នែកមួយនៃព្រំដែនរបស់កម្ពុជា។ ខ្ញុំព្រះករុណាខ្ញុំ ទ្រាំឈឺចាប់លើបញ្ហានេះអស់រយៈកាលរហូតមកដល់ពេលនេះ បើគិតពីឆ្នាំ២០០៥ ហើយមុននោះទៅទៀត គឺយូរណាស់មកហើយ ឈឺចាប់ពេកហើយ ខ្ញុំព្រះករុណាខ្ញុំ មិនអាចនឹងទទួលរ៉ាប់រងទូលផែនដីកម្ពុជាម្នាក់ឯងបាននោះទេ នៅពេលខ្ញុំព្រះករុណាខ្ញុំចង់ការពារទឹកដី តើមានអ្នកណាមកការពារខ្ញុំព្រះករុណាខ្ញុំ ក្រៅពីការវាយប្រហារជាន់ពន្លិចបន្ថែមដើម្បីយកការឈ្នះឆ្នោតតែប៉ុណ្ណោះ។ តើខ្ញុំព្រះករុណាខ្ញុំខុសអ្វីទៅដែលគ្រាន់តែធ្វើការតស៊ូដើម្បីផលប្រយោជន៍ជាតិឱ្យបារាំងមានការចរចាជាមួយវៀតណាម ដើម្បីទាញយកខ្សែផែនទីដែលគូសទៅតាមព្រែកដាក់ដាំ ឱ្យមកដើរតាមព្រែកដាក់ហ៊ូតស្របតាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន តើខ្ញុំព្រះករុណាខ្ញុំខុសឬទេ? តើនេះជាស្មារតីក្បត់ជាតិ ឬក៏ជាស្មារតីស្នេហាជាតិ?

ឥឡូវ សូមមើលផែនទីរបស់គណបក្សសង្គ្រោះជាតិម្តង ដែលចាត់ទុកខ្លួនឯងថាជាផែនទីត្រឹមត្រូវ។ គណបក្សសង្គ្រោះជាតិនៅជំពាក់ផែនទីចំនួន២ផ្ទាំង មានមួយផ្ទាំងនោះគាត់យកផែនទីឥណ្ឌូចិនទាំងមូលកម្ពុជា វៀតណាម ឡាវ គាត់យកមកដាក់បង្គោះតាម ហើយមានមួយផ្ទាំងនោះ អាហ្នឹងគឺដីវៀតណាមទាំងអស់ហ្នឹង គឺថានៅបានមិនថុក នៅខេត្តដាឡាករបស់វៀតណាម គាត់នៅជំពាក់២ផ្ទាំងទៀត ប៉ុន្តែឥឡូវសូមមើល ខ្ញុំព្រះករុណាខ្ញុំ នឹកស្មានថា ផែនទីរបស់សង្គ្រោះជាតិអាចមានភាពប្រសើរទៅលើចំនុចដែលគាត់អាចរកឃើញនូវភាពខ្លាំងខ្លះ ដែលអាចផ្តល់នូវទឡ្ហីករណ៍ឱ្យរាជរដ្ឋាភិបាលយកទៅចរចាជាមួយវៀតណាម មិន

នឹកស្មានផែនទីនេះ គឺគ្រាន់តែជាផែនទីបោកប្រាស់ ហើយសាហាវជាងសត្វអាសិរពិស ឥឡូវចំនុចដាក់ដាំ ដាក់ហ៊ុត គឺដូចគ្នាតែម្តង។ នេះគឺព្រែកដាក់ដាំដដែល នេះគឺដាក់ហ៊ុតដដែលខ្ញុំព្រះករុណាខ្ញុំទើបតែគូសព្រឹកមិញនេះ។ អញ្ចឹងទេ តើសង្គ្រោះជាតិមានអ្វីប្រសើរជាងផែនទីរដ្ឋាភិបាលបើវាដូចគ្នាជាមួយផែនទីរដ្ឋាភិបាល ហើយអន់ជាងរាជរដ្ឋាភិបាលទៅទៀត រាជរដ្ឋាភិបាលកំពុងតែទាមទារឱ្យវៀតណាមគូសបន្ទាត់មកតាមព្រែកដាក់ហ៊ុតទៅតាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន តើនេះឬជាទង្វើស្នេហាជាតិរបស់សង្គ្រោះជាតិ របស់មេដឹកនាំតែម្តង ហើយចោទគេថាប្រើផែនទីក្លែងក្លាយ ក្នុងពេលដែលគេកំពុងតែព្យាយាមចរចាដើម្បីធ្វើម៉េចឱ្យស្របទៅនឹងសេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន។ អ្នកណាស្នេហាជាតិ អ្នកណាក្បត់ជាតិ យើងមិនចង់និយាយអ្នកណាក្បត់ជាតិ ប៉ុន្តែគេប្រើភាសាមកលើយើងអាក្រក់ណាស់ សាហាវណាស់ ពិសពុលណាស់ ឥឡូវបានចេញមកកណ្តាលវាលហើយ តំបន់ដាក់ដាំ ដាក់ហ៊ុត គឺគ្មានអ្វីខុសគ្នាជាមួយនឹងផែនទីដែលយកទៅអង្គការសហប្រជាជាតិ។ បន្ថែមលើនោះ ផែនទីបារាំងដែលបញ្ជូនមក គឺដដែលដូចគ្នាទាំងអស់ អញ្ចឹងតើខ្ញុំព្រះករុណាខ្ញុំតស៊ូនេះ ឬមកពីខ្ញុំព្រះករុណាខ្ញុំមិនព្រមតស៊ូ មិនព្រមលះបង់ តំបន់ដាក់ដាំ ដាក់ហ៊ុត ទើបសង្គ្រោះជាតិចោទខ្ញុំថាផែនទីក្លែងក្លាយ។ សួរបែបនេះទៅវិញ មេដឹកនាំរបស់គេគួរតែ ឆ្លើយដោយមានការគោរព និងមានសីលធម៌ បើផែនទីរបស់អ្នកឯងវាដូចបេះបិទរបស់ផែនទីរាជរដ្ឋាភិបាល បន្ថែមលើនោះ អ្នកឯងជំពាក់២ផ្ទាំងនេះទៅទៀត ក្នុងពេលដែលខ្ញុំព្រះករុណាខ្ញុំសរសេរសំបុត្រទៅឱ្យប្រធានាធិបតីបារាំង គេបង្ហោះថាទិញត្រឹមតែ១៦៨ដុល្លារទេ សូមអ្នកនាំពាក្យនិយាយឱ្យច្បាស់ អាមួយបង់ថ្លៃសេវា អាមួយទិញ។ នៅក្នុងហ្វេសប៊ុក គេប្រើភាសាទិញ ជាវបាន ប៉ុន្តែអ្នកនាំពាក្យបែរមកជាធ្វើការកែតម្រូវ ខ្ញុំគិតថា ប្រជាពលរដ្ឋ និងអ្នកបច្ចេកទេសទាំងឡាយថតរក្សាទុកអស់ហើយ ក្រោយពេលបង្ហោះអាហ្នឹង រួចមកហើយទើបសរសេរ SMS មកឱ្យខ្ញុំថាសូមកែមាត្រា២នៃរដ្ឋធម្មនុញ្ញ។ ការសុំកែមាត្រា២នៃរដ្ឋធម្មនុញ្ញ គឺមិនមែនបណ្ឌិត **សុខ ទូច** ឬអ្នកណាផ្សេងក្រៅពីឯកឧត្តម **សម រង្ស៊ី** ទេ។ ខ្ញុំព្រះករុណាខ្ញុំ ចង់បង្ហាញបន្ថែមទៀត ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីចំណុចនេះ ព្រោះមាននៅសល់នៅក្នុងនេះនៅឡើយទេ ដើម្បីយើងអានឱ្យស្តាប់ទាំងអស់គ្នា ឱ្យយល់ទាំងអស់គ្នា ខ្លួនឯងជាអ្នកបង្កើតបញ្ហា រួចហើយទម្លាក់ឱ្យអ្នកដទៃដោយគ្មានការទទួលខុសត្រូវ សូមអស់លោកចាប់យកទៅ នេះហើយជា SMS ជាសារទូរស័ព្ទរបស់ឯកឧត្តម **សម រង្ស៊ី** មកចំពោះខ្ញុំ ហើយខ្ញុំអានឱ្យស្តាប់អំពីចំណុចនេះ ដើម្បីជៀសវាងសមាជិកសមាជិកា និងថ្នាក់ដឹកនាំនៃគណបក្សប្រឆាំង ឬបក្សដទៃយកធ្វើជាល្បែងរហូតទៅដល់ដេរក្រុមស្រាវជ្រាវឯករាជ្យ។ នៅថ្ងៃសុក្រ ទី១៧ ខែកក្កដា ម៉ោង ៧:៤៩នាទីព្រឹក ឯកឧត្តម **សម រង្ស៊ី** បានសរសេរមកឱ្យខ្ញុំថា «ជម្រាបសួរសម្តេច ខ្ញុំសូមអបអរសាទរប្រសាសន៍ថ្មីៗនេះរបស់សម្តេចទាក់ទងនឹងបញ្ហាព្រំដែន។ ដើម្បីបង្ហាញពីឯកភាពជាតិឱ្យកាន់តែរឹងមាំក្នុងបំណងការពារបូរណភាពទឹកដីរបស់កម្ពុជា ខ្ញុំសូមសម្តេចមេត្តាពិនិត្យ លទ្ធភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់មាត្រា២ស្តីពីផែនទីដែលយើងត្រូវបញ្ជាក់ឱ្យកាន់តែក្បោះក្បាយ ដោយមានការចូលរួមគាំទ្រពីគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិរួមគ្នា ដោយសេចក្តីគោរពរាប់អានពីខ្ញុំ» ដល់ខ្ញុំឆ្លើយត្រឡប់ទៅវិញគឺ «មិនមានការចាំបាច់ធ្វើនៅពេលនេះទេ»។ អញ្ចឹងខ្លួនឯងជាអ្នកបបួលគេធ្វើ គេបានដឹងរឿងនេះយូរហើយ គេអត់មានត្រូវការធ្វើក្នុងពេលនេះទេ ខ្លួនឯងបបួលគេធ្វើ ហើយចង់ថាយកអាផែនទីនេះឆ្នាំ១៩១៤ អត់មានទេផែនទីឆ្នាំ ១៩១៤ សូមផ្តាំត្រឡប់ទៅវិញ កុំលួងពេក។ អញ្ចឹងឥឡូវវាចេញមកទាំងអស់ហើយ ខ្ញុំព្រះករុណាខ្ញុំបានបញ្ជាក់ប្រាប់អំពីចំណុចទាក់ទិនជាមួយតំបន់ដាក់ដាំ ដាក់ហ៊ុត ខ្ញុំព្រះករុណាខ្ញុំ ទ្រាំទ្រលែងកើតជាមួយនឹង

ការប្រមាថមាក់ងាយសព្វបែបយ៉ាង ការចរចាជាមួយវៀតណាមនៅតែបន្តធ្វើ មិនបោះបង់ចោលទេ ដោយយើងបានមើលសណ្ឋានអត្ថទេសាភិបាលឥណ្ឌូចិនបានឱ្យដើរតាមព្រែកដាក់ហ្សិត បន្ថែមលើនោះ តាមព្រែកដាក់ហ្សិតមានបង្គោលព្រំដែនមួយចំនួន។ ហើយមួយទៀត ទោះបីផែនទីដើរតាមព្រែកដាក់ដាំ ប៉ុន្តែព្រែកដាក់ដាំពុំមានបង្គោលព្រំដែនទេ នេះជាចំនុចដែលកម្ពុជានៅបន្តការពិភាក្សាជាមួយវៀតណាម ប៉ុន្តែសូមបញ្ជាក់ថា យើងមិនអាចលើកកងទ័ពទៅដណ្តើមយកទឹកដីនោះបានទេ វាហួសសម័យហើយ យើងមិនអាចធ្វើតាម **អាភីស៊ីត** នៅប្រទេសថៃបានទេ។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥ ខ្ញុំព្រះករុណាខ្ញុំ ក៏បានធ្វើលិខិតទៅមេដឹកនាំនៃប្រទេសចំនួន៣ទៀត គឺសាធារណរដ្ឋបារាំង សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេសក្នុងគោលដៅស្វះស្វែងរកកិច្ចសហការស្នើសុំខ្ចីផែនទី និងស្នើសុំអ្នកជំនាញខាងផែនទីដើម្បីផ្ទៀងជាមួយផែនទីផ្លូវការ និងស្របច្បាប់ ខ្នាត១/១០០ពាន់ ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់ក្នុងការកំណត់ និងការបោះបង្គោលព្រំដែនជាមួយវៀតណាម។ ជាលទ្ធផលចក្រភពអង់គ្លេស តាមរយៈលិខិតចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ របស់ឯកឧត្តមនាយករដ្ឋមន្ត្រី David Cameron បានឆ្លើយតបជាផ្លូវការថាចក្រភពអង់គ្លេសពុំបានរកឃើញនូវផែនទីដូចដែលកម្ពុជាស្នើសុំនោះទេ។ ចំណែកឯសាធារណរដ្ឋបារាំងវិញតាមរយៈលិខិតចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ របស់ឯកឧត្តមប្រធានាធិបតី François Hollande បានឆ្លើយតបជាវិជ្ជមានទៅនឹងសំណើរបស់កម្ពុជា ដោយបានសម្រេចប្រគល់ឱ្យកម្ពុជានូវផែនទីចម្លងនៃផែនទីខ្នាត១/១០០ពាន់ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិនចំនួន២៦ផ្ទាំង តាមរយៈស្ថានទូតបារាំងប្រចាំកម្ពុជា។ ដោយឡែកសហរដ្ឋអាមេរិកពុំទាន់បានឆ្លើយជាផ្លូវការទៅនឹងសំណើរបស់កម្ពុជានៅឡើយទេ ក៏ប៉ុន្តែយើងក៏សូមបញ្ជាក់ដែរថា ផែនទីរបស់អាមេរិកត្រូវបានឯកឧត្តម **វ៉ា គឹមហុង** ទៅថតយកមកតាំងពីជាង១០ឆ្នាំមុននោះ ឥឡូវនេះក្នុងផ្ទះខ្ញុំព្រះករុណាខ្ញុំពោរពេញទៅដោយផែនទីតែម្តង ទាំងផែនទីមកបារាំង ទាំងផែនទីមកពីសង្គ្រោះជាតិ ទាំងផែនទីមកពីអាមេរិក ទាំងផែនទីមកពីអង្គការសហប្រជាជាតិ ពោរពេញដោយផែនទី។ អញ្ចឹងផែនទីដែលអ្នកខ្លះបានអួតអាងថាបានរកឃើញ ហើយរដ្ឋាភិបាលថារកមិនឃើញ គេយកមកទុកនៅទីនេះ តាំងពីជាង១០ឆ្នាំនោះ ហើយផ្ទៀងផ្ទាត់ទៅវាអត់មានខុសអីទេ វានៅតែដដែលហ្នឹង អញ្ចឹងអាមេរិកឱ្យឬក៏មិនឱ្យ គឺនៅតែដដែលហ្នឹង ឱ្យក៏អរ មិនអោយក៏បាន ព្រោះយើងមានរួចទៅហើយក៏ប៉ុន្តែចង់បានឱ្យមានជាផ្លូវការតែប៉ុណ្ណឹងទេ ពីមុនផ្លូវការទៅហើយ គេបោះត្រាចេញពីបណ្ណាល័យហើយនោះ ប៉ុន្តែយើងចង់បានពីសំណាក់រដ្ឋាភិបាលទៅរដ្ឋាភិបាល វាល្អជាង។ ផ្អែកលើលទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់នេះ ដើម្បីសម្រួលការងារទទួល ប្រគល់ និងផ្ទៀងផ្ទាត់ការងារ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មការចំពោះកិច្ចដែលមានសមាសភាពចំនួន១១រូប មកពីក្រសួងស្ថាប័ននានា និងដឹកនាំដោយ ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គណៈកម្មការចំពោះកិច្ចនេះបានធ្វើការយ៉ាងហ្មត់ចត់ក្នុងលក្ខណៈបើកចំហ និងប្រកបដោយតម្លាភាពពេញលេញ និងដោយមានការចូលរួមត្រួតពិនិត្យ និងសង្កេតការណ៍យ៉ាងទូលំទូលាយពីគ្រប់តួអង្គពាក់ព័ន្ធ ជាអាទិ៍ តំណាងគណបក្សនយោបាយ តំណាងរដ្ឋសភា តំណាងព្រឹទ្ធសភា តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តំណាងរាជបណ្ឌិតសភា ព្រមទាំងទីប្រឹក្សារាជរដ្ឋាភិបាលដែលមានសញ្ជាតិបរទេសមួយចំនួន ដើម្បីផ្ទៀងផ្ទាត់ផែនទីពីអង្គការសហប្រជាជាតិ និងពីសាធារណរដ្ឋបារាំង។

ការផ្ទៀងផ្ទាត់ផែនទីដែលអង្គការសហប្រជាជាតិបានឱ្យខ្ចី ជាមួយផែនទីផ្លូវការ និងស្របច្បាប់របស់រដ្ឋាភិបាលកម្ពុជាបានប្រព្រឹត្តទៅ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ លទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីនេះ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ ដោយគ្មានការសង្ស័យ អំពីភាពត្រឹមត្រូវដូចគ្នាបេះបិទ រវាងខ្សែបន្ទាត់ព្រំដែននៃផែនទីដើមដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទី១ បានប្រើប្រាស់ជាផ្លូវការ ហើយដែលអង្គការសហប្រជាជាតិបានអនុញ្ញាតឱ្យកម្ពុជាខ្ចីជាមួយនឹងផែនទីព្រំដែននៃផែនទីផ្លូវការ និងស្របច្បាប់ ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់ សម្រាប់កំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។ ការផ្ទៀងផ្ទាត់ផែនទីច្បាប់ចម្លង ដែលសាធារណរដ្ឋបារាំងបានប្រគល់ឱ្យជាមួយផែនទីផ្លូវការ និងស្របច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា បានប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥។ ខ្ញុំព្រះករុណាខ្ញុំ សុំគូសបញ្ជាក់ឡើងវិញម្តងទៀតថា សាធារណរដ្ឋបារាំង តាមរយៈស្ថានទូតរបស់ខ្លួនប្រចាំប្រទេសកម្ពុជា បានប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជានូវផែនទីច្បាប់ចម្លងចំនួន២៦ផ្ទាំង ដែលទទួលបានពីវិទ្យាស្ថានភូមិសាស្ត្រប្រទេសបារាំង ផែនទីទាំង២៦ផ្ទាំងនេះ គឺជាផែនទីខ្នាត១/១០០ពាន់ ដែលធ្វើឡើងដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ក្នុងនោះ២៥ផ្ទាំងជាប្រភេទផែនទីបោន និងមួយផ្ទាំងជាប្រភេទផែនទី UTM ។ ផែនទីនេះត្រូវបានធ្វើនៅក្នុងចន្លោះឆ្នាំ១៩៣៣-១៩៥៣ ផែនទីដែលទទួលបានពីបារាំងនៅពេលនោះ គឺជាផែនទីដែលមានសារសំខាន់ជាទីបំផុត ព្រោះផែនទីនេះផលិតឡើងដោយបារាំង ហើយពេលនោះបារាំងជាអាណាព្យាបាលលើកម្ពុជា ជាអ្នកកំណត់ព្រំដែនរវាងកម្ពុជា និងសៀម រវាងកម្ពុជាជាមួយកូសាំងស៊ីន និងរវាងកម្ពុជាជាមួយឡាវ។ ព្រំដែនដែលកំណត់ដោយបារាំងនោះបានបន្សល់ជាមរតក និងជាមូលដ្ឋានសម្រាប់កម្ពុជាយកមកប្រើប្រាស់ក្រោយទទួលបានឯករាជ្យស្របតាមគោលការណ៍ខ្សែព្រំដែនមិនកែប្រែ។ ជាថ្មីម្តងទៀតលទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីដោយបើកចំហ និងប្រកបដោយតម្លាភាពនេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ ដោយគ្មានសង្ស័យ អំពីភាពត្រឹមត្រូវដូចគ្នាបេះបិទរវាងខ្សែព្រំដែនទាំង២៦ផ្ទាំងដែលផលិត ដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន និងដែលទទួលបានពីបារាំងជាមួយនឹងខ្សែព្រំដែនផ្លូវការ និងស្របច្បាប់ទាំង២៦ផ្ទាំងដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់សម្រាប់កំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។ ខ្ញុំព្រះករុណាសូមបញ្ជាក់នៅក្នុងចំណុចនេះបន្តិច រវាងផែនទីដែលយកពីអង្គការសហប្រជាជាតិ១៨ផ្ទាំង ពិតមែនតែជាផែនទីមិនមែនតម្កល់នៅអង្គការសហប្រជាជាតិ ហើយក៏មិនមែនជាផែនទីបោន តែជាផែនទី UTM ខ្នាត១/១០០ពាន់ ប៉ុន្តែសូមបញ្ជាក់ថា បារាំងបានធ្វើផែនទីទាំង២បែប ពិតមែនតែខ្ញុំព្រះករុណាខ្ញុំមិនមែនអ្នកឯកទេសផែនទី ក៏ប៉ុន្តែដើម្បីយល់ដឹងអំពីបញ្ហាទឹកដី ខ្ញុំព្រះករុណាខ្ញុំ បានស្វះស្វែងសិក្សាស្វែងយល់អំពីផែនទីដែលបារាំងបានធ្វើ ទាំងផែនទីបោន និងផែនទី UTM អញ្ចឹងផែនទីដែលយកមកពីអង្គការសហប្រជាជាតិជាប្រភេទផែនទី UTM ប៉ុន្តែយកមកផ្ទៀងផ្ទាត់ជាមួយផែនទីបោន ដែលជាផែនទីដើម ដែលចុះហត្ថលេខារវាងកម្ពុជា និងវៀតណាម គឺដូចគ្នាទាំងស្រុងរាប់ទាំងតំបន់ជាក់ជាំ ជាក់ហ្នឹងតែម្តង គឺដូចគ្នាទាំងស្រុង អញ្ចឹងចំណុចនេះ គឺទោះ UTM ឬបោន គឺវាដូចគ្នា សម្រាប់មកពីបារាំង មកពីអង្គការសហប្រជាជាតិមិនមែនបោនទេ គឺផែនទី UTM ប៉ុន្តែគឺបារាំងជាអ្នកធ្វើទាំងពីរ បារាំងមានទាំងពីរ។ ហើយពេលដែលយើងផ្ទៀងផ្ទាត់ជាមួយផែនទី ផែនទីបារាំងគឺផែនទីសំខាន់ណាស់ មកពីកន្លែងផ្សេងគឺជារឿងមួយ ប៉ុន្តែមកពីបារាំងដោយសារអ្វី? បារាំងជាអ្នកកំណត់ព្រំដែនឱ្យយើងជាមួយនឹងសៀម កាលពេលនោះសៀមឥឡូវថៃ ឱ្យយើង

ជាមួយកូសាំងស៊ីន ឥឡូវវៀតណាមឱ្យយើងជាមួយនឹងឡាវ ឱ្យយើងជាព្រំប្រទល់រដ្ឋបាលរវាងកម្ពុជា និងអណ្ណាម ឥឡូវកូសាំងស៊ីន និងអណ្ណាមទៅជាវៀតណាមតែមួយ អញ្ចឹងសំខាន់ណាស់ផែនទីមកពីបារាំង។

ខ្ញុំព្រះករុណាខ្ញុំ សុំទូលប្រគេនចំពោះព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិថា ខ្ញុំព្រះករុណាខ្ញុំ បានប្ដេជ្ញាចិត្តរួចហើយថា ប្រសិនបើផែនទីមកពីបារាំងខុសគ្នាជាមួយផែនទីដែលចុះហត្ថលេខាជាមួយនឹងវៀតណាម ខ្ញុំព្រះករុណាខ្ញុំនឹងប្រកាសលាលែងពីតំណែងភ្លាម មិនធ្វើនាយករដ្ឋមន្ត្រីតទៅទៀត ហើយក៏ស្ម័គ្រចិត្តចូលទៅកាន់មន្ទីរឃុំឃាំងរង់ចាំតុលាការកាត់ទោសតែម្ដង ព្រោះនេះជាការទទួលខុសត្រូវជាប្រវត្តិសាស្ត្រដ៏ធំធេង ហ៊ានស៊ីហ៊ានសង ចិត្តជាកូនប្រុស ព្រោះយើងអត់ដឹងផែនទីមកពីបារាំងវាធុនណាទេ? ហេតុអ្វីបានលោកហ៊ុនសែនហ៊ានលេង? សុំពីសហប្រជាជាតិមិនដឹងថា ពីសហប្រជាជាតិផែនទីបែរមុខទៅណា? សុំពីអាមេរិកថែមទាំងមិនច្បាស់ សុំពីអង់គ្លេស ប៉ុន្តែអស់គ្លេសយើងដឹងថា វាមិនច្បាស់ហើយបានន័យថា ប្រសិនបើមាន ប៉ុន្តែគាត់ឆ្លើយថាអត់មាន ប៉ុន្តែរឿងដែលធំជាងគេគឺផែនទីដើមដែលបារាំងអ្នកធ្វើ អញ្ចឹងល្បែងមួយចាននេះគឺជាល្បែងដែល **ហ៊ុន សែន** ត្រូវធ្វើអត្តឃាតនយោបាយបញ្ចប់សេចក្ដីតែម្ដង។ ហើយរឿងនេះ គឺជារឿងដែលខ្ញុំព្រះករុណាខ្ញុំបានគិតនៅថ្ងៃទី៦ បញ្ជាមកភ្នំពេញឱ្យធ្វើលិខិតល្ងាចថ្ងៃទី២៦ បញ្ជាទាំងជាមួយរដ្ឋមន្ត្រីការបរទេស បញ្ជាមកឯកឧត្ដម **អូន ព័ន្ធមុនីរ័ត្ន** ក្នុងឋានៈជាប្រធានឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចដែលធ្លាប់តែធ្វើឯកសារឱ្យខ្ញុំព្រះករុណាខ្ញុំ ធ្វើពីភ្នំពេញទៅផង ដើម្បីផ្ទុំគ្នាទាំង២ទិស ពីក្រសួងការបរទេស និងពីឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ច ដោយធ្វើផ្ទាល់ពីឯកឧត្ដម **អូន ព័ន្ធមុនីរ័ត្ន** ខ្ញុំព្រះករុណាខ្ញុំបានចុះហត្ថលេខាតាំងពីយប់ថ្ងៃទី៦ ប៉ុន្តែវាគ្មានត្រាបោះ ពេលដែលកំពុងស្នាក់នៅឯទីក្រុង នៅខេត្តមួយរបស់ជប៉ុន។ បានសេចក្ដីថា ខ្ញុំព្រះករុណាខ្ញុំបានតាំងចិត្ត ល្បែងមួយនេះគឺល្បែងបញ្ចប់ជីវិតនយោបាយ ឬក៏ល្បែងត្រូវឈ្នះ រហូតដល់ពេលណាដែលខ្ញុំព្រះករុណាខ្ញុំឈប់ចង់ធ្វើ ហើយអ្នកដែលប្រឆាំងត្រូវទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ហើយខ្ញុំព្រះករុណាខ្ញុំនឹងលេងគេរហូតដល់តម្លៃណាក៏ដោយ ព្រោះគេមិនបានទុកឱ្យយើងសុខ គ្មានពេលណាដែលយើងត្រូវទុកឱ្យគេសុខនោះទេ។ ខ្ញុំព្រះករុណាខ្ញុំ ពិតជាប្រថុយប្រថានជាមួយនឹងគ្រោះថ្នាក់ធំណាស់ ប្រសិនបើផែនទីមកពីបារាំងបែរជាខុសជាមួយផែនទីដែលចុះហត្ថលេខាជាមួយវៀតណាម ពេលនោះហើយដែលខ្ញុំព្រះករុណាខ្ញុំប្រកាសលាលែងចេញពីតំណែង គណបក្សប្រជាជនត្រូវជ្រើសរើសនូវមេដឹកនាំថ្មី នេះជាការដឹងតែខ្ញុំព្រះករុណាខ្ញុំតែម្នាក់គត់ មិនឱ្យប្រពន្ធ មិនឱ្យកូន និងមិនឱ្យសមាជិកបក្សមានការភ័យព្រួយទេ។ អញ្ចឹងទេបានជានៅពេលដែលផ្ទៀងផ្ទាត់ពីអង្គការសហប្រជាជាតិ ខ្ញុំព្រះករុណាខ្ញុំអត់ដាក់កម្មវិធីទៅណាទេ នៅមើលការផ្ទៀង ដល់ពេលផ្ទៀងរបស់បារាំង គឺសំខាន់ជាងការផ្ទៀងរបស់មកពីអង្គការសហប្រជាជាតិ ព្រោះមកពីអង្គការសហប្រជាជាតិ គឺជាផែនទីដែលយើងបញ្ជូនទៅប្ដឹង ហើយមិនគ្រប់ទៅទៀត បានតែ១៨ផ្ទាំង លើ២៦ផ្ទាំង អញ្ចឹងត្រូវបញ្ជាឱ្យគ្រប់ស្ថានីយទូរទស្សន៍ទាំងអស់ផ្សាយបន្តផ្ទាល់ បើសិនជាពេលនោះឃើញថា មានការខុសគ្នា ក្នុងពេលតំណាលគ្នាគឺនឹងមានការប្រកាសផ្សាយបន្តផ្ទាល់អំពីការប្រកាសលាលែងពីតំណែងរបស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បញ្ចប់ការកាន់អំណាចរយៈពេលជាង៣ទសវត្សរ៍របស់ខ្លួន ប៉ុន្តែអ្វីៗបានច្បាស់ហើយ ទេវតាមានភ្នែក ទេវតាពិតជាមិនដាក់ទណ្ឌកម្មចំពោះអ្នកដែលប្រព្រឹត្តនូវអំពើល្អនោះទេ ហើយទេវតាបាននឹងកំពុងដាក់បណ្ដាសារទៅលើពួកអ្នកដែលបានធ្វើអំពើអាក្រក់ អ្នកខ្លះកំពុងរត់ចោលស្រុក អ្នកខ្លះនៅក្នុងមន្ទីរឃុំឃាំង នេះខ្ញុំព្រះករុណាខ្ញុំ សូមទូលប្រគេន និងជម្រាបជូនពីអាថ៌កំបាំងលើរឿងនេះ ភរិយាខ្ញុំព្រះករុណាខ្ញុំ កូនចៅខ្ញុំព្រះករុណាខ្ញុំ អត់មានអ្នកណាដឹង អ្នកធ្វើការជិត

ស្និទ្ធបំផុត ក្រៅពីខ្ញុំម្នាក់ឯង អត់មានអ្នកណាដឹង។ ហើយថ្ងៃនេះខ្ញុំព្រះករុណាខ្ញុំបកស្រាយ ប្រសិនជាផ្ទៀងទៅបែរជាខុស គឺបានន័យថា **ហ៊ុន សែន** ដល់ទីបញ្ចប់របស់ខ្លួនហើយ នេះជាល្បែងប្រថុយនឹងគ្រោះថ្នាក់ ប៉ុន្តែវាត្រូវតែលេង ព្រោះជាប្រយោជន៍របស់ជាតិ ខ្ញុំព្រះករុណាខ្ញុំបាននិយាយហើយថា មិនមែនជាដីរបស់ម្ដាយខ្ញុំព្រះករុណាខ្ញុំទៀតទេ មានន័យថាមេច? បើគ្រាន់តែជាដីរបស់ម្ដាយខ្ញុំព្រះករុណាខ្ញុំ យ៉ាងច្រើនបងប្អូនបង្កើតរបស់ខ្ញុំព្រះករុណាខ្ញុំ កូនរបស់ខ្ញុំព្រះករុណាខ្ញុំ ក្មួយរបស់ខ្ញុំព្រះករុណាខ្ញុំតែប៉ុណ្ណោះដែលនឹងធ្វើការស្តីបន្ទោសខ្ញុំព្រះករុណាខ្ញុំពីការបាត់កេរមរតកនេះ ប៉ុន្តែប្រសិនបើដីនេះបាត់ ដីជាតិបាត់ ជាតិទាំងមូលនឹងធ្វើការស្តីបន្ទោសខ្ញុំព្រះករុណាខ្ញុំ នេះជាល្បែងដ៏គ្រោះថ្នាក់ ប៉ុន្តែជាល្បែងប្រកបដោយការទទួលខុសត្រូវ ខ្ញុំព្រះករុណាខ្ញុំប្រកាសលាលែងពីតំណែង ហើយខ្ញុំព្រះករុណាខ្ញុំនឹងធ្វើដំណើរទៅកាន់មន្ទីរឃុំឃាំងដោយខ្លួនឯង។ ប៉ុន្តែឥឡូវឆ្លើយតបមកវិញ ផ្ទៀងផ្ទាត់ត្រឹមត្រូវ ហើយអ្នកទាំងឡាយទទួលខុសត្រូវបែបណាវិញ? ចំពោះមុខប្រវត្តិសាស្ត្រ សូម្បីតែផែនទីខ្លួនឯងដែលបង្ហោះថាល្អខ្លាំងណាស់ នេះហើយចេះធ្វើឱ្យផែនទីរស់ ខ្ញុំអត់ចេះដែរ។ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បងប្អូនជនរួមជាតិទាំងឡាយ ផែនទីរស់របៀបម៉េចនោះ គេបង្ហោះតាម Facebook ថា ចាក់ទៅធ្វើឱ្យផែនទីវារស់ ខ្ញុំក៏មិនយល់ដែរអត់ដឹងទេ ប្រហែលជាយើងរៀនមិនទាន់ដល់ ប្រហែលជាត្រូវការ៥០០ឆ្នាំអីទៀតក៏មិនដឹង ប៉ុន្តែយើងអត់ត្រូវការផែនទីបញ្ចេញតាម Photocopy ទេ បញ្ចេញតាម DVD ទេ យើងត្រូវការពីអង្គការសហប្រជាជាតិនូវផែនទីដើមយកមក យើងចេញចំណាយសម្រាប់មន្ត្រីអង្គការសហប្រជាជាតិ យើងត្រូវការពីបារាំងនូវផែនទីជាក្រដាស ព្រោះយកមកនេះជួនកាលគ្រាន់តែ Print ចេញ បោះពុម្ពចេញ ក្រដាសវារួញ វាអាចនឹងមានភាពលំអៀងរបស់វា។ អញ្ចឹងចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំ បាននិយាយបញ្ជាក់ជូនជនរួមជាតិអំពីអ្វីដែលជាអាថ៌កំបាំងលាក់ទុក ដែលខ្ញុំព្រះករុណាខ្ញុំបានទូលប្រគេននេះ មួយចានទឹកមួយចានគោគ ឬមួយបន្តកាន់អំណាចដោយមានការជឿជាក់ពីប្រជាពលរដ្ឋ ឬមួយត្រូវលាលែងចេញពីតំណែង តាមរយៈការផ្ទៀងផ្ទាស់ផែនទីមិនត្រូវ ដូច្នេះត្រូវលាលែងពីតំណែង។ ឥឡូវអ្នកដែលយកមកចោទគេថាផែនទីក្លែងក្លាយ តើហ៊ានលាលែងពីតំណែងឬអត់? នេះជាចម្លើយបកត្រឡប់ទៅវិញ អំពីការទទួលខុសត្រូវរៀងខ្លួនលើមុខប្រវត្តិសាស្ត្ររបស់ជាតិ ការកុតកុហកដែលមានចរិតគ្រោះថ្នាក់ឱ្យជាតិ គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ខ្ញុំព្រះករុណាខ្ញុំប្រើពាក្យថាជាការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយជាឧក្រិដ្ឋជនតែម្តង។

បន្ថែមពីលើនេះ ក្នុងគោលដៅធានាឱ្យបានកាន់តែច្បាស់លាស់ ជម្រះស្រឡះអស់នូវមន្ទិលសង្ស័យ រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តដល់ក្រុមស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា ដែលជាស្ថាប័នវិទ្យាសាស្ត្រឯករាជ្យ ដឹកនាំដោយលោកបណ្ឌិត **សុខ ទូច** ហើយធ្វើការស្រាវជ្រាវទៅលើបញ្ហាព្រំដែននេះផងដែរ ក្រុមស្រាវជ្រាវនេះបានដំណើរការប្រមូលឯកសារពាក់ព័ន្ធនឹងបញ្ហាព្រំដែនប្រទេសកម្ពុជា ជាមួយប្រទេសវៀតណាម ពិសេសផែនទីរដ្ឋរវាងប្រទេសទាំង២ ពីប្រភពនានា ហើយទទួលបាននូវផែនទីផ្លូវការដែលប្រើប្រាស់ដោយរាជរដ្ឋាភិបាលចំនួន២៦ផ្ទាំង ផែនទីពីគណបក្សសង្គ្រោះជាតិចំនួន២៤ផ្ទាំង ផែនទីពីបណ្ណាល័យព្រឹទ្ធសភាអាមេរិកចំនួន២៦ផ្ទាំង ផែនទីពីអង្គការសហប្រជាជាតិចំនួន១៨ផ្ទាំង និងផែនទីពីបណ្ណាល័យភូមិសាស្ត្រជាតិបារាំងចំនួន២៦ផ្ទាំង ក្រុមស្រាវជ្រាវនៃរាជបណ្ឌិតសភាបានធ្វើការផ្ទៀងផ្ទាត់ដែលប្រមូលបានទាំងអស់ដោយមានការចូលរួមពីសមាជិករដ្ឋសភានៃគណបក្សទាំងពីរ សមាជិកព្រឹទ្ធសភា និងតំណាងរាជរដ្ឋាភិបាលព្រមទាំងតួអង្គពាក់ព័ន្ធនានា។ លទ្ធផលនៃការផ្ទៀងផ្ទាត់នេះ ត្រូវបានបង្ហាញឱ្យឃើញតាមរយៈសន្និសីទ

សារព័ត៌មានកាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ថា ផែនទីដែលរាជរដ្ឋាភិបាលបាននឹងកំពុងប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយវៀតណាម គឺជាផែនទីត្រឹមត្រូវច្បាស់លាស់ ហើយផែនទីដែលទទួលបានពីប្រភពនានា ដោយរួមទាំងផែនទីដែលទទួលបានពីគណបក្សសង្គ្រោះជាតិផង គឺដូចគ្នាទៅនឹងផែនទីផ្លូវការរបស់រាជរដ្ឋាភិបាល ពិតមែនតែខ្ញុំព្រះករុណាខ្ញុំបានហៅថា ផែនទីសង្គ្រោះជាតិមកពីគណបក្សសង្គ្រោះជាតិ គឺជាផែនទីដែលថាមានចរិតសាហាវជាងសត្វអាសិរពិស គឺត្រង់ចំណុចថាគេលាក់ផែនទីនេះទុកយូរពេក ហើយយកអាចំណុចនោះទៅបោកប្រាស់ប្រជាជន និងបន្ទុះបង្កាប់ផែនទីរបស់រាជរដ្ឋាភិបាល តែខ្ញុំព្រះករុណាខ្ញុំមិនបានហៅផែនទីសង្គ្រោះជាតិជាផែនទីក្លែងក្លាយទេ ព្រោះផែនទីនេះវាដូចគ្នានឹងផែនទីរបស់រាជរដ្ឋាភិបាលដែរ វានៅខ្វះតែពីរផ្ទាំងតែប៉ុណ្ណោះ ហើយសង្ឃឹមថាសង្គ្រោះជាតិនឹងរកផែនទី២ផ្ទាំងនេះទៅជូនឯកឧត្តម **សុខ ទូច** ខ្ញុំក៏បានស្នើសុំខ្ចីបន្តពីឯកឧត្តម **សុខ ទូច** យកមក ដើម្បីធ្វើការនៅថ្ងៃនេះដែរ ព្រោះគេមិនបានផ្តល់ឱ្យខ្ញុំព្រះករុណាខ្ញុំទេ គេមិនបានដាក់លក្ខខណ្ឌឱ្យឧត្តម **សុខ ទូច** មិនឱ្យអ្នកណាគេខ្ចីទេ ព្រោះគេថាអាហ្នឹងទិញបានផង អញ្ចឹងមានអ្វីពិបាក ប៉ុន្តែយើងមិនចង់យកពីកន្លែងណាទេ ចង់យករបស់គេហ្នឹងតែម្តង យកមកប្រើថាតើវាដូចគ្នាដែរឬអត់។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំ ឆ្លៀតក្នុងឱកាសនេះ សូមថ្លែងមូលវិចារដ៏ថ្លៃថ្លា ជូនចំពោះក្រុមស្រាវជ្រាវនៃរាជបណ្ឌិតសភា ដែលបានធ្វើការនេះប្រកបដោយវិជ្ជាជីវៈ ឯករាជ្យភាព និងតម្លាភាពទូលំទូលាយ រាជរដ្ឋាភិបាលលើកទឹកចិត្តដល់ក្រុមស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា ហើយបន្តសកម្មភាពសិក្សាស្រាវជ្រាវនេះតទៅទៀត រួមបញ្ចូលទាំងការពិនិត្យផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវវាងផែនទី និងបង្គោលព្រំដែនដែលបានបោះហើយផងដែរ។ ហើយកន្លងទៅក៏មានការបង្ហោះ Facebook ដើម្បីគំរាមសម្លាប់បណ្ឌិត **សុខ ទូច** រាជរដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវ ហើយស្វែងរកចាប់ខ្លួនជនល្មើសឱ្យបានផងដែរ ហើយតុលាការកំពុងស្រាវជ្រាវករណីនេះជាបន្ត។

### IV.ការសន្និដ្ឋាន និងការងារបន្ត

សរុបសេចក្តីទៅ ការពិនិត្យឡើងវិញអំពីសាវតារ និងទិដ្ឋភាពច្បាប់បានបញ្ជាក់ច្បាស់ថា ផែនទីផ្លូវការដែលជាផែនទីបោន ខ្នាត១/១០០ពាន់ ធ្វើនៅឆ្នាំ១៩៣៣ ឆ្នាំ១៩៥៣ ដែលរាជរដ្ឋាភិបាលបាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម គឺជាផែនទីស្របច្បាប់ពេញលេញ ទាំងតាមច្បាប់ជាតិ ទាំងតាមច្បាប់អន្តរជាតិ។ លើសពីនេះទៀត លទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទីក៏បានបង្ហាញឱ្យឃើញយ៉ាងច្បាស់អស់ការសង្ស័យដែរថា ផែនទីដែលអតីតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទី១ ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ជាព្រះប្រមុខរដ្ឋ បានប្រើប្រាស់ជាផ្លូវការដើម្បីប្តឹងទៅអង្គការសហប្រជាជាតិ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និងផែនទីបោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលសាធារណរដ្ឋបារាំងបានប្រគល់ឱ្យរាជរដ្ឋាភិបាលកម្ពុជានោះ គឺមានលក្ខណៈដូចគ្នាបេះបិទទៅនឹងផែនទីផ្លូវការ និងស្របច្បាប់ ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់សម្រាប់កំណត់ និងបោះបង្គោលព្រំដែនជាមួយវៀតណាម លទ្ធផលដូចគ្នាបេះបិទនេះត្រូវបានធានា តាមរយៈកិច្ចដំណើរការផ្ទៀតផ្ទាត់ ប្រកបដោយលក្ខណៈបើកចំហ និងប្រកបដោយតម្លាភាពពេញលេញ និងដោយទូលំទូលាយ ទោះបីការផ្ទៀងផ្ទាត់នេះធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ឬធ្វើឡើងដោយស្ថាប័នឯករាជ្យផ្សេងទៀត ដូចជាក្រុមស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជាក៏ដោយ។ ហេតុនេះការចោទប្រកាន់

ថាផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រើប្រាស់សម្រាប់កំណត់ និងបោះបង្គោលព្រំដែន ជាមួយវៀតណាម គឺជាផែនទីក្លែងក្លាយ ឬជាផែនទីមិនត្រឹមត្រូវ រហូតដល់ថាជាផែនទីចោរទៀតនោះ គឺការមួលបង្កាច់ដោយគ្មានមូលដ្ឋានច្បាស់លាស់ និងយ៉ាងអយុត្តិធម៌បំផុត មកលើរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ការចោទប្រកាន់មួលបង្កាច់ដោយគ្មានការទទួលខុសត្រូវ គឺបានបង្ហាញឱ្យឃើញកាន់តែច្បាស់អំពីល្បិចកលដ៏ពិសពុល និងការមិនញញើតភ្លាចច្បាប់រដ្ឋរបស់មជ្ឈដ្ឋានប្រឆាំង សំដៅញុះញង់ បំផុស បំផុល បំភ្លៃបំភ្លើស កាឡៃការពិត និងសភាពការណ៍ដែលទាក់ទងនឹងព្រំដែនជាមួយវៀតណាម ដើម្បីបង្កើតឱ្យមានការយល់ច្រឡំ និងមិនត្រឹមត្រូវលើបញ្ហាព្រំដែន ក្នុងគោលបំណងបោកបញ្ឆោតទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនប្រជាពលរដ្ឋ។

ចំពោះមុខប្រជាពលរដ្ឋជាទីស្នេហារបស់ខ្លួន ដើម្បីគេអាចប្រើប្រាស់ជាឧបករណ៍អាជីវកម្មនយោបាយរបស់គេ និងមិនខ្វាយខ្វល់ និងការទទួលខុសត្រូវចំពោះជោគវាសនា និងផលប្រយោជន៍របស់ជាតិនោះឡើយ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលសូមសង្កត់ធ្ងន់ថា ទន្ទឹមនឹងការបន្តលើកស្ទួយ និងគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងការបញ្ចេញមតិ ក៏ដូចជាការធ្វើនយោបាយ រាជរដ្ឋាភិបាលក៏នឹងបន្តចាត់វិធានការសមស្របដោយគ្មានការលើកលែង និងប្រកបដោយភាពម៉ឺងម៉ាត់ តាមនីតិរដ្ឋ និងវិធាននៃច្បាប់ចំពោះជនទាំងឡាយដែលហ៊ានធ្វើសកម្មភាពរំលោភបំពានច្បាប់ នៅក្រោមផ្លាកសិទ្ធិនយោបាយ និងសិទ្ធិនៃការបញ្ចេញមតិ។ នៅក្នុងសង្គមប្រជាធិបតេយ្យ និងនីតិរដ្ឋ អ្នកនយោបាយ ក៏ដូចជាប្រជាពលរដ្ឋទូទៅ អ្នកណាក៏ដោយ ឱ្យតែប្រព្រឹត្តល្មើសច្បាប់ត្រូវតែទទួលខុសត្រូវ តាមការកំណត់នៃបទបញ្ញត្តិច្បាប់គ្មានការលើកលែង។ ចំណុចនេះ ខ្ញុំព្រះករុណាខ្ញុំសូមបញ្ជាក់ជូនថា ចាប់ពីពេលនេះតទៅ អ្នកណាក៏ដោយដែលហ៊ាននិយាយថាផែនទីក្លែងក្លាយ ផែនទីមិនត្រឹមត្រូវ ផែនទីចោរ ត្រូវចាប់ខ្លួនបន្ទាន់ ដែលនេះជាបទបញ្ជាដាច់ខាតមួយត្រូវតែធ្វើ ព្រោះនេះជាគ្រោះថ្នាក់សម្រាប់ជាតិ ព្រោះវាអាចបង្កើតកំហឹងឆាបឆេះតាមរយៈទឹកចិត្តស្នេហាជាតិរបស់ប្រជាពលរដ្ឋ គ្រប់រូបដែលស្រលាញ់ទឹកដីរបស់ខ្លួន ហើយត្រូវបានរាជរដ្ឋាភិបាលកាត់ទៅឱ្យបរទេស តាមរយៈផែនទីមិនត្រឹមត្រូវ។

ដូចនេះ បើសិនជាទុកឱ្យមានរឿងនេះកើតឡើង នោះសង្គ្រាមនឹងអាចផ្ទុះ ហើយសូមបញ្ជាក់ថា ក្រៅពីគណបក្សប្រជាជន គណបក្សដទៃកាន់អំណាចនឹងមានសង្គ្រាមដាច់ខាត។ ខ្ញុំព្រះករុណាខ្ញុំ សូមអះអាងថានឹងមានសង្គ្រាម ព្រោះគេហ៊ានធ្វើតាំងពីពេលនេះនូវពាក្យពេចន៍បែបនេះ។ ពិតមែនហើយកាលពីថ្ងៃសុក្រអាទិត្យមុន ក្នុងពេលប្រជុំគណៈរដ្ឋមន្ត្រី មានអ្នកបង្ហោះតាមហ្វេសប៊ុកថា កុំបន្ទោសខ្មែរគ្នាឯង ព្រោះដីខ្មែរបាត់តាំងពី៤០០ឆ្នាំមុន តាំងពីគណបក្សប្រជាជន គណបក្សសង្គ្រោះជាតិមិនទាន់កើត។ ចុះបើលោកនិយាយបែបនេះដដែល ម្ដេចលោកជេរខ្ញុំប៉ុន្មានឆ្នាំមកហើយ។ ឥឡូវបកស្រាយហ្វេសប៊ុករបស់លោកឯង វាយ៉ាងម៉េចទៅវិញ? ឯកឧត្តម **សម រង្ស៊ី** តែម្ដងគាត់ថា បាត់តាំងពីជំនាន់ជ័យជេដ្ឋាទី២ ៤០០ឆ្នាំមុន តាំងពីគណបក្សប្រជាជន គណបក្សសង្គ្រោះជាតិមិនទាន់កើត អញ្ចឹងអ្នកឯងជេរខ្ញុំប៉ុន្មានឆ្នាំហើយ ទាំងឯកឧត្តម **សម រង្ស៊ី** ផ្ទាល់ និងអ្នកដឹកនាំឯកឧត្តម ទទួលខុសត្រូវបែបណា? បើសាភោពបែបនេះហើយ ត្រូវហ៊ានទទួលខុសត្រូវបន្តទៀត ត្រូវហ៊ានសុំទោស ហោចណាស់ក៏ត្រូវហ៊ានទទួលខុសត្រូវខាងសីលធម៌ដែរ ដែលយល់ថាយើងបានជេរគេថាលក់ទឹកដី ធ្វើឱ្យបាត់ដីរាប់ពាន់ រាប់ម៉ឺនគីឡូម៉ែតការ៉េ តើអ្នកឯងហ៊ានទទួលខុសត្រូវទេ? នេះ

បើចិត្តជាកូនប្រុសដូចដែលខ្ញុំបាននិយាយដូចអំបាញ់មិញនេះ បើផ្ទៀងទៅឃើញថាខុស ខ្ញុំនឹងលាចេញពីតំណែង ឥឡូវលោកឯងហ៊ានឬទេ?

ខ្ញុំគ្រាន់តែសូមបញ្ជាក់ថា ខ្ញុំមិនអត់ឱនឱ្យនរណាមួយដែលបន្តប្រើពាក្យផែនទីមិនត្រឹមត្រូវ ផែនទីក្លែងក្លាយ ផែនទីចោរ ហើយក៏សូមបញ្ជាក់ បើគេមិនឱ្យខ្ញុំសុខ ខ្ញុំក៏មិនឱ្យគេសុខដែរ។ ខ្ញុំកំពុងស្ថិតនៅក្នុងអំណាច ខ្ញុំអត់ទៅធ្វើអ្វីខុសនោះទេ តែបើអ្នកឯងប្រើឯកសារក្លែងក្លាយ អ្នកឯងមកចោទគេថាក្លែងក្លាយដោយទទឹងទិស អ្នកឯងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ អញ្ជឹងអ្នកអនុវត្តច្បាប់ មន្ត្រីអនុវត្តច្បាប់ទាំងអស់ត្រូវចាប់ខ្លួននៅនឹងកន្លែង ចំពោះអ្នកណាក៏ដោយដែលប្រើពាក្យ ឬភាសានេះ ព្រោះជាការបំពានច្បាប់យ៉ាងពិតប្រាកដ។ យ៉ាងហោចក៏ត្រូវមើលព្រះរាជក្រមប្រកាសដាក់ឱ្យប្រើនូវច្បាប់ទាក់ទងទៅនឹងសន្ធិសញ្ញា និងផែនទីនេះ។ នេះជាមូលដ្ឋានដែលខ្ញុំព្រះករុណាខ្ញុំ ហ៊ានចេញបទបញ្ជា ព្រោះបើមិនចេញបទបញ្ជាបែបនេះ តើនរណាជាអ្នកចេញបទបញ្ជាក្រៅពីនាយករដ្ឋមន្ត្រី? រឿងបទល្មើសជាក់ស្តែងត្រូវតែចាប់ខ្លួនភ្លាម។ មិនមែនជាការគំរាមកំហែង សិទ្ធិនយោបាយត្រូវធ្វើ ក៏ប៉ុន្តែមិនត្រូវឱ្យឈានទៅដល់កម្រិតចោទប្រកាន់គេ។ រាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំ ក្នុងឋានៈជាប្រមុខរាជរដ្ឋាភិបាលនេះ គោរពទាំងស្រុងនូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិ គោរពទាំងស្រុងនូវសកម្មភាពនយោបាយទាំងឡាយណាដែលស្របច្បាប់ ប៉ុន្តែមិនលើកលែង និងមិនអត់ឱនដាច់ខាតជាមួយអ្នកណាក៏ដោយ ដែលនៅបន្តបំពានលើករណីទាក់ទិនជាមួយនឹងបញ្ហាផែនទី និងព្រំដែន គឺមិនអាចយោគយល់។

គេធ្លាប់និយាយថា យោគយល់ចំពោះសត្រូវ គឺព្រៃផ្សៃចំពោះខ្លួនឯង គឺថាពិតប្រាកដណាស់។ កន្លងទៅការយោគយល់របស់ខ្ញុំព្រះករុណាខ្ញុំបានត្រឹមតែធ្វើបាបខ្លួនឯងតែប៉ុណ្ណោះ។ លើកលែងទោសឱ្យអ្នកដទៃម្តងហើយម្តងទៀត អ្នកនោះតែងតែធ្វើបាបខ្លួនឯងជានិច្ច។ នេះសមនឹងអ្វីដែលគេនិយាយថា យោគយល់ចំពោះសត្រូវ គឺព្រៃផ្សៃចំពោះខ្លួនឯង។ តែខ្ញុំព្រះករុណាខ្ញុំស្មោះស្ម័គ្រធ្វើដោយចិត្តឯង តែពីពេលនេះមិនយោគយល់ដាច់ខាត ចំពោះជម្ងឺដដែលៗ និងមនុស្សដដែលៗ ដែលប្រព្រឹត្តនូវកំហុសដដែលបែបនេះ។ មិនមែនជាការគំរាមកំហែងនោះទេ ប៉ុន្តែប្រទេសប្រជាធិបតេយ្យត្រូវអមដោយនីតិរដ្ឋ មិនអាចបំពាននីតិរដ្ឋបានទេ។ អនុវត្តច្បាប់ដោយគ្មានការលើកលែង ទោះអ្នកនោះជាអ្នកណាក៏ដោយ។ តទៅមុខទៀត រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា នៅតែបន្តការប្តេជ្ញាចិត្តដ៏មោះមុត ឥតងាករេក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន សំដៅកសាងឱ្យបាននូវខ្សែបន្ទាត់ព្រំដែនមួយស្ថាពរ និងអចិន្ត្រៃយ៍ជាមួយប្រទេសជិតខាង ប្រកបដោយភាពច្បាស់លាស់ត្រឹមត្រូវ សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ និងធានាឱ្យបានដាច់ខាតថាបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នឹងមិនបាត់បង់ឡើយ សូម្បីតែមួយម៉ែត្រក្រឡាក៏ដោយ។ លើមូលដ្ឋាននៃគោលនយោបាយនេះ រាជរដ្ឋាភិបាលនឹងបន្តប្រកាន់ខ្ជាប់ខ្លួន និងប្រកបដោយសង្គតិភាពនូវគោលការណ៍ជាយុទ្ធសាស្ត្រមួយចំនួន នៅក្នុងការខិតខំដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង រួមមាន ៖

**ទី១. ធានាការពារឱ្យបានដាច់ខាតនូវអធិបតេយ្យភាព និងបូរណភាពទឹកដី**

ដោយឈរលើគោលការណ៍ជាមូលដ្ឋាននៃខ្សែព្រំដែនមិនកែប្រែ នៅពេលដែលកម្ពុជាបានឯករាជ្យ ដូចមានកំណត់ក្នុងមាត្រា២ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមចំនុច២មាត្រា១ឃ នៃកិច្ចព្រមព្រៀងប៉ារីសថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១។ ខ្ញុំព្រះករុណាខ្ញុំ ក៏ចង់យកឱកាសនេះ ដើម្បីបង្ហាញបន្តិចអំពី

បញ្ហាពាក់ព័ន្ធជាមួយនឹងបញ្ហាកិច្ចព្រមព្រៀងប៉ារីសដែលមនុស្សមួយចំនួនតែងទន្ទេញចាំមាត់ ក្នុងពេលដែលខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្លួននេះឯងដែលជាអ្នកចរចាយ៉ាងម៉ឺងម៉ាត់ជាច់ខាត ហើយគឺជាអ្នកដែលបានរួមចំណែកតាំងពីដើមទី ដើម្បីសម្រេចបានកិច្ចព្រមព្រៀងមួយនេះ។ ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់ថា ចំនុចយ ទាក់ទិនជាមួយនឹងបញ្ហាបញ្ចប់សន្និសញ្ញា។ សូមបញ្ជាក់ជូនបន្តិចដើម្បីឱ្យឃើញទាំងអស់គ្នា ត្រង់ចំនុចយនេះគេបានបញ្ជាក់ បញ្ចប់សន្និសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលមិនស្របទៅនឹងអធិបតេយ្យភាព ឯករាជ្យបូរណភាព និងភាពមិនអាចរំលោភបាននៃដែន ដីអព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ខ្លួន។ អញ្ចឹង ខ្ញុំព្រះករុណាខ្ញុំ ចង់បញ្ជាក់ជូននូវចំនុចនេះបន្តិច ប្រសិនបើរដ្ឋធម្មនុញ្ញកម្ពុជាបានចេញមកថា អធិបតេយ្យភាពរបស់កម្ពុជាប្រើប្រាស់តាមផែនទីខ្នាត១/៥០ពាន់ កិច្ចព្រមព្រៀងនេះរលាយជាស្វ័យប្រវត្តិ ប៉ុន្តែហេតុអ្វីបានជាកិច្ចព្រមព្រៀងនេះវានៅស្ថិតស្ថិរ? ដោយសាររដ្ឋធម្មនុញ្ញរបស់ យើងបានកំណត់ព្រះរាជាណាចក្រកម្ពុជាប្រើប្រាស់ផែនទីខ្នាត១/១០០ពាន់ ធ្វើនៅចន្លោះឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣ ដល់១៩៦៩។ អញ្ចឹង កិច្ចព្រមព្រៀងនោះវាស្របទៅនឹងរដ្ឋធម្មនុញ្ញនេះឯង វាអត់មានខុស ប៉ុន្តែបើរដ្ឋធម្មនុញ្ញចេញមកថាអោយប្រើផែនទីខ្នាត១/៥០ពាន់ ឬខ្នាត១/២០០ពាន់ខុសទៅនឹងនេះ គឺបានសេចក្តីថា កិច្ចព្រមព្រៀងនេះរលាយជាស្វ័យប្រវត្តិ។ ឆ្លងកាត់មកដល់ ព្រះរាជាណាចក្រកម្ពុជាទី២ ឯកសារនេះមិនមែនជាឯកសាររបស់អតីតរដ្ឋសាធារណរដ្ឋប្រជាមានិតកម្ពុជាទៀតទេ មិនមែនជាឯកសាររបស់រដ្ឋកម្ពុជាទៀតទេ តែជាឯកសារផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាទី២។ ខ្ញុំសូមស្នើឱ្យអ្នកច្បាប់ទាំងឡាយ ក៏ដូចជាអ្នកសិក្សាទាំងឡាយ អាននូវភាគទី១ ការរៀបចំក្នុងដំណាក់ការអន្តរកាលផ្នែកទី១ ដំណាក់ការអន្តរកាល និងមាត្រាទី១នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីងាយយល់ ព្រោះអ្នកខ្លះអត់ដឹងកិច្ចព្រមព្រៀងប៉ារីសបែរមុខទៅណាក៏ហ៊ានមកនិយាយធ្វើឯងជាខ្លាំងពូកែ។ ខ្ញុំអាននូវចំនុចនេះអោយបានច្បាស់បន្តិច ៖

មាត្រា១ ៖ ដើម្បីបម្រើវត្ថុបំណងនៃកិច្ចព្រមព្រៀងនេះ ដំណាក់ការអន្តរកាលត្រូវចាប់ផ្តើមពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយត្រូវបញ្ចប់នៅពេលដែលសភាធម្មនុញ្ញដែលបានជាប់ឆ្នោត តាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដែលរៀបចំឡើង និងបញ្ជាក់ដោយអង្គការសហប្រជាជាតិ និងអនុម័តរដ្ឋធម្មនុញ្ញ ហើយបានក្លាយខ្លួនជាទៅជាសភានីតិបញ្ញត្តិ រួចបន្ទាប់មករដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើង។ អញ្ចឹងឥឡូវនេះ ៥អាណត្តិហើយ ៥អាណត្តិកន្លះរួចទៅហើយ ដែលកិច្ចព្រមព្រៀងនេះបានបន្ត **សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ** ទៅជាមួយ វៀតណាម បន្ថែមមកទៀត**សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ** ក្នុងឋានៈជាព្រះប្រធានរដ្ឋសភានៅពេលនោះ ក្នុងនាមហ្វុនស៊ិនប៉ិច ព្រះមហាក្សត្រយើងបានឡាយព្រះហស្ថលេខា លើអ្វីដែលកំពុងមានសព្វថ្ងៃ មិនមែនជារបស់អតីតរដ្ឋកម្ពុជាអ្វីតទៅទៀតទេ គឺជារបស់ព្រះរាជាណាចក្រ ដែលស្របនឹងរដ្ឋធម្មនុញ្ញ ហើយសុំកុំភាន់ច្រឡំទៅលើការ បន្តអនុវត្តទៅលើកិច្ចព្រមព្រៀងប៉ារីសតទៅទៀត។ ធាតុនៃកិច្ចព្រមព្រៀងប៉ារីសទាំងអស់បានចូលមកក្នុងរដ្ឋធម្មនុញ្ញ កម្ពុជារួចអស់ទៅហើយ។ កុំភាន់ច្រឡំ ព្រោះមានមនុស្សមួយចំនួនចូលចិត្តនិយាយយ៉ាងពេញៗមាត់ ទៅលើកិច្ចព្រមព្រៀងប៉ារីស ដោយមិនដឹងថាកិច្ចព្រមព្រៀងប៉ារីសចែងពីអ្វី តើនៅក្រោមអាណានិគមរបស់អង្គការសហប្រជាជាតិរហូតទៅឬយ៉ាងម៉េច? គេបានកំណត់យ៉ាងច្បាស់នៅមាត្រាទី១ នៅពេលណាដែលមានការបោះឆ្នោត ហើយមានសភាធម្មនុញ្ញ សភាធម្មនុញ្ញធ្វើរដ្ឋធម្មនុញ្ញហើយ សភានឹងក្លាយទៅជាសភានីតិបញ្ញត្តិ មានរាជរដ្ឋាភិបាល ហើយបានសេចក្តីថា

ប្រតិបត្តិការរបស់អង្គការសហប្រជាជាតិត្រូវបញ្ចប់ហើយ **អាកាស៊ី សាទ្រី សន់ដឺសន់** ចេញតាំងពីយប់អាធ្រាតថ្ងៃទី២៤ ខែកញ្ញា បន្ទាប់ពីរដ្ឋធម្មនុញ្ញបានប្រកាសឱ្យប្រើ នេះត្រូវអោយឃើញ។ អ្នកដែលនិយាយអំពីបញ្ហានេះ ត្រូវមើលតម្លៃនៃកិច្ចព្រមព្រៀងប៉ារីសពេលនេះ តើវាស្មើគ្នានឹងតំលៃរដ្ឋធម្មនុញ្ញ និងតម្លៃនៃព្រះរាជក្រមដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ និងដែលមាននីតិប្រតិបត្តិ និងនីតិបញ្ញត្តិ។ ហើយ ៥អាណត្តិរួចមកហើយ ឥឡូវអាណត្តិទី៥ ៤អាណត្តិកន្លះ ចាត់ទុកថាចឹងទៅចុះ ៥អាណត្តិទៅហើយ។ សុំកុំភាន់ច្រឡំតទៅទៀត មិនមែនជារបស់គណបក្សប្រជាជន តែជារបស់ជាតិកម្ពុជាទាំងមូល។អញ្ចឹងសុំឱ្យភ្លឺភ្នែក សុំឱ្យអ្នកដែលនិយាយពីកិច្ចព្រមព្រៀងប៉ារីសអានពីកិច្ចព្រមព្រៀងប៉ារីសពីដើមរហូតដល់ចប់។ ហើយដំបូងបំផុត សុំមើលមាត្រា១ ភាគទី១ ការរៀបចំក្នុងដំណាក់ការអន្តរកាល គេចងនៅក្នុងនឹង ដើម្បីចៀសវាងអង្គការសហប្រជាជាតិដាក់អាណានិគមមួយជីវិត។ វាបញ្ចប់ត្រង់ពេលដែលគេមានសភា គេមានរដ្ឋធម្មនុញ្ញគេមានស្ថីស្ថីរបស់គេ វាចប់ទៅហើយ។ ឥឡូវ គេដំណើរការមិនទៅសុំច្បាប់ UNTAC អីណា SNC មិនមានបន្តនៅទៀតឯណា ខ្លះនៅក្នុងគុក SNC **ខៀវ សំផន** នៅក្នុងគុកនៅឡើយ។ និយាយរួម SNC ស្លាប់អស់ប្រហែលជាពាក់កណ្តាលទៅហើយ មានអីទៀត ហើយមករកអីទៀត មិនប្រើរដ្ឋធម្មនុញ្ញរបស់ខ្លួន ទៅប្រើកិច្ចព្រមព្រៀងប៉ារីស ហើយយកមកដើម្បីបោកប្រជារាស្ត្រ។

**ទី២. ឈរលើមូលដ្ឋាននៃគោលការណ៍ទី១ខាងលើ**

ធានាឱ្យបានខ្សែព្រំដែនមួយច្បាស់លាស់ ដោយប្រែក្លាយខ្សែព្រំដែនដែលមានតែលើផែនទី ឱ្យទៅជាបង្គោលព្រំដែននៅលើដីជាក់ស្តែង ហើយខ្សែព្រំដែននេះទៀតសោត នៅពេលណាដែលភាគីទាំងសង្ខាងបញ្ចប់ការបោះបង្គោល និងខ័ណ្ឌសីមារួចរាល់ហើយ គឺត្រូវស្របគ្នាទៅនឹងការកាន់កាប់ជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែនទាំងសងខាង។

**ទី៣. អនុវត្តការងារនៅក្នុងចំនុចទី២ខាងលើ ក្នុងស្មារតីសន្តិភាពមិត្តភាព សហប្រតិបត្តិការ និងការសម្រុះសម្រួលក្នុងឋានៈជារដ្ឋអធិបតេយ្យ ដែលជាដៃគូស្មើភាព និងស្មើសិទ្ធជាមួយគ្នា ដោយឈរលើមូលដ្ឋាននៃច្បាប់ជាតិ និងអន្តរជាតិ។**

**ទី៤. កសាងព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ដែលនឹងផ្តល់ផលប្រយោជន៍ដ៏ពិតប្រាកដដល់ប្រទេស និងប្រជាជនដែលចូលរួមពាក់ព័ន្ធទាំងអស់ ជាពិសេសប្រជាពលរដ្ឋនៅតាមព្រំដែន។**

ឥឡូវ ខ្ញុំព្រះករុណាខ្ញុំ ចង់សួរប្រជាពលរដ្ឋដែលរស់នៅតាមទល់ដែន តើចង់បានសង្គ្រាមរឺទេ? ខ្ញុំព្រះករុណាខ្ញុំ យល់ថា បើសិនសង្គ្រាមផ្ទុះតាមទល់ដែន មិនថាទល់ដែនខាងកើត ឬទល់ដែនខាងលិច ឬទល់ដែនណាទេ ហើយមិនថាទូទាំងព្រំដែនទេ សូម្បីតែចំនុចតូចណាមួយក៏ដោយ គឺវាមិនល្អសម្រាប់ប្រទេសជាតិទាំងមូល ការអភិវឌ្ឍបានរបស់ប្រទេសជាតិមួយ ចំនុចរបស់វាមានកត្តាអនុគ្រោះផ្ទៃក្នុង និងកត្តាអនុគ្រោះជាអន្តរជាតិ ដែលរាប់ទាំងទំនាក់ទំនងជិតខាងល្អ។ ការធ្វើពាណិជ្ជកម្មព្រំដែលល្អរវាងកម្ពុជា និងថៃ មានទំហំជាង ៥ពាន់លានដុល្លារសហរដ្ឋអាមេរិកកាលពីឆ្នាំទៅ ៥ពាន់៤រយលានដុល្លារសហរដ្ឋអាមេរិក។ ការធ្វើពាណិជ្ជកម្មរវាងព្រំដែនកម្ពុជា និងវៀតណាម ជិត៤ពាន់លានដុល្លារសហរដ្ឋអាមេរិក កាលពីឆ្នាំទៅជាមួយឡាវគឺតូចល្មមទេ ប៉ុន្តែបើសិនប្រទេសទាំងពីរមានជម្លោះជាមួយគ្នា តើប្រជាជនអាចរស់នៅបានក្រៅពីរត់លូនទេ? យើងធ្លាប់បានឃើញប្រជាជនភៀសសឹកនៅតំបន់ព្រះវិហារ ធ្លាប់បានឃើញប្រជាជនភៀសសឹកនៅឧត្តរមានជ័យ

ទេ? នេះហើយជាលទ្ធផលនៃសង្គ្រាម ហើយនេះហើយជាលទ្ធផលដែលវានឹងមកដល់នៅពេលដែលគណបក្សប្រឆាំងកាន់អំណាច វានឹងមកដល់នៅពេលដែលគណបក្សប្រជាជនមិនកាន់អំណាចតទៅទៀត វាច្បាស់នឹងមកដល់បើបក្សដទៃកាន់អំណាច។ ខ្ញុំព្រះករុណាខ្ញុំ និយាយពេញមាត់ មានតែគណបក្សប្រជាជនមួយគត់ដែលធានាថា គ្មានជម្លោះទល់ដែនជាមួយប្រទេសជិតខាង លើកលែងតែប្រទេសជិតខាងលើកទ័ពចូលកម្ពុជាម្តងម្កាល ដូចដែលករណីវត្តកែវសិក្ខាគិរីស្វារៈ បង្ខំចិត្តត្រូវតែធ្វើការតស៊ូប្រដាប់អាវុធ។ ទីនេះហើយដែលខ្ញុំព្រះករុណាខ្ញុំអង្គុយបញ្ជាតាម Video Conference ទៅកាន់ព្រំដែន យើងមិនចង់ឃើញស្ថានភាពបែបនេះ មានការស្លាប់ មានការរបួស មានការខូចខាតទ្រព្យសម្បត្តិសម្រាប់ប្រជាពលរដ្ឋ។ ខ្ញុំព្រះករុណាខ្ញុំ ជឿជាក់ថា មិនត្រឹមតែប្រជាពលរដ្ឋនៅតាមព្រំដែនទេ ប្រជាពលរដ្ឋនៅទូទាំងប្រទេស ព្រោះនៅពេលដែលសភាពការណ៍កើតឡើង មិនមែនគ្រាន់តែប៉ះពាល់តែប្រជាជននៅតាមទល់ដែន ប្រជាពលរដ្ឋនៅទូទាំងផ្ទៃប្រទេសគឺប៉ះពាល់ទាំងអស់ សូម្បីតែអ្នកធ្វើខាងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច សិល្បករសិល្បការិនី កីឡាករ កីឡាការិនី ក៏ប៉ះពាល់ទាំងអស់។ សូមកុំសង្ឃឹមបក្សប្រឆាំងដែលគេចិញ្ចឹមចិត្តប្រឆាំងទៅលើបញ្ហា ហើយជំងឺជាតិសាសន៍ជ្រុលនិយមរបស់ពួកគេធ្ងន់ធ្ងរខ្លាំងពេកហើយ។ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយ និងគោលការណ៍យុទ្ធសាស្ត្រនេះ ចំពោះការចរចាកំណត់ និងបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាម រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការងារជាក់ស្តែងដែលនៅសេសសល់ចំនួនដូចខាងក្រោម ៖

**ទី១.បន្តការចរចារហូតដល់ចប់សព្វគ្រប់លើការកំណត់ និងបោះបង្គោលព្រំដែនដោយហ្មត់ចត់ និងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ដោយឈរលើគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងលិខិតូបករណ៍ពាក់ព័ន្ធ រួមទាំងផែនទីស្របច្បាប់ និងផ្លូវការដែលមានជាធរមាន និងដោយប្រើប្រាស់យន្តការនៃស្ថាប័នសមត្ថកិច្ចជាធរមាន**

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងជាមួយភាគីវៀតណាមរួចហើយ ដើម្បីដោះស្រាយករណីដែលអាចមានការមិនឯកភាពគ្នាផ្នែកបច្ចេកទេស ឬមានភាពមិនច្បាស់លាស់លើចំនុចណាមួយនៃផែនទី តាមរយៈការស្រុះស្រួលគ្នារវាងភាគីទាំងពីរក្នុងការស្នើសុំ ឬជួលអ្នកជំនាញការបរទេសដែលឯករាជ្យឱ្យមកជួយពិនិត្យផ្ទៀងផ្ទាត់ ឬផ្តល់ការបំភ្លឺតាមការចាំបាច់។ ខ្ញុំព្រះករុណាខ្ញុំ បានលើកជាមួយបេសកជនពិសេសរបស់វៀតណាម ហើយអាទិត្យមុននេះក្នុងការប្រជុំគណរដ្ឋមន្ត្រី ខ្ញុំព្រះករុណាខ្ញុំបានណែនាំចំពោះឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី **វ៉ា គឹមហុង** ប្រធានគណៈកម្មាការចម្រុះព្រំដែន ដើម្បីធ្វើអោយមានការចរចាជាមួយវៀតណាមពិតប្រាកដ និងមានកំណត់ហេតុ ចំនុចណាដែលមិនចុះសម្រុងគ្នាលើបញ្ហាបច្ចេកទេស ក្នុងនោះមានទាំងការផ្ទេរ ផែនទីបោនមកកាន់ផែនទី UTM ត្រូវរកការជួលរឺសុំអ្នកបច្ចេកទេសពីបរទេស បើសិនសុំបានជាការល្អ ដូចជាបារាំង ប្រធានាធិបតីបារាំងបាននិយាយថាមិនអាចជូនអ្នកបច្ចេកទេសមកបានទេ វាលើកលែងតែភាគីទាំងពីស្នើសុំ បើដូច្នោះយើងក៏ត្រូវឆ្លៀតប្រើនូវសំដីរបស់ប្រធានាធិបតីបារាំង François Hollande អំពីចំនុចនេះ អញ្ចឹងយើងនឹង វៀតណាមរួមគ្នាស្នើសុំអ្នកបច្ចេកទេសផែនទី ដើម្បីមកពិនិត្យ ហើយច្បាស់ណាស់ថាទាំងការជួលគេ ទាំងគេឱ្យ ប្រហែលជាខ្លះគេអោយជាជំនួយឥតសំណង ខ្លះគេអាចឱ្យយើងជាអ្នកបច្ចេកទេស ប៉ុន្តែអោយយើងទទួលបន្ទុកចំណាយ។ ខ្ញុំព្រះករុណាខ្ញុំ ឱ្យគោលការណ៍ទៀតចែកគ្នាចាយពាក់កណ្តាលម្នាក់ វៀតណាមចំណាយពាក់កណ្តាល កម្ពុជាចំណាយពាក់កណ្តាល រាប់ទាំងថ្លៃសំបុត្រយន្តហោះអ្នកនឹងជិះ ដេកអូតែលអស់ប៉ុន្មាន បើថាអស់១០ម៉ឺនដុល្លារ ចេញ៥ម៉ឺនម្នាក់ កុំខ្លាចអស់

លុយ។ បញ្ហាទឹកដីជាបញ្ហាសំខាន់ រឿងលុយកាក់វាជារឿងសំខាន់ហើយ តែវាមិនសំខាន់ជាងរឿងទឹកដីដែលជូនតាទុកអោយទេ។

**ទី២. បន្តការផ្ទៀងផ្ទាត់រវាងផែនទី និងបង្គោលព្រំដែនដែលបានបោះរួចជាក់ស្តែងដោយហ្មត់ចត់ និងប្រកបដោយតម្លាភាព ដើម្បីធានាភាពត្រឹមត្រូវច្បាស់លាស់ពិតប្រាកដ**

ទន្ទឹមនឹងការធានានូវភាពរឹងមាំ និងភាពជឿទុកចិត្តបាននៃបង្គោល។ ការផ្លាស់បង្គោលចាស់ជំនួសដោយបង្គោលថ្មីដែលរឹងមាំល្អ ក៏ដូចជាការកំណត់ និងការបោះបង្គោលថ្មី ត្រូវអនុវត្តស្របតាមនីតិវិធីប្រកបដោយតម្លាភាពបំផុត។ ចំនុចនេះត្រូវធ្វើ កុំឱ្យផែនទីដើរទៅតាមផ្លូវម្ខាងបង្គោលព្រំដែនទៅតាមផ្លូវម្ខាង។ បារាំងធ្លាប់ធ្វើបែប នេះបារាំងធ្លាប់ធ្វើបែបនេះ។ សេចក្តីសម្រេចរបស់អគ្គទេសាភិបាលឥណ្ឌូចិន ឱ្យដើរតាមព្រែកដាក់ហ៊ុត ប៉ុន្តែដល់ទៅគូសផែនទីតាមព្រែកដាក់ដាំ ដល់បោះបង្គោល បោះតាមព្រែកដាក់ហ៊ុត។ បារាំងធ្លាប់ធ្វើ។ អាហ្នឹងចំណុចដែលខ្ញុំចំណាំបាន ដែលខ្ញុំស្គាល់វា ដែលខ្ញុំដឹងវា។ ចំណុចមួយទៀត បង្គោល៣១៤ ចំណុចចុងក្រោយដែលយើងបោះចុងក្រោយ។ បារាំងខ្ជិល បារាំងបោះតាំងពីសម័យដើម គឺបារាំងខ្ជិល បោះអត់ត្រូវតាមចំណុចផែនទីទេ។ អញ្ចឹងបានពីរវាងបង្គោលចាស់ និងបង្គោលថ្មី គឺមានចំណុចខុសគ្នា។ ដល់យើងរុករកទាល់តែឃើញចំណុច ទើបយើងបោះ។ បង្គោលនោះជាបង្គោលចាស់។ អញ្ចឹងអត់មាន វៀតណាមក៏មិនខាត កម្ពុជាក៏មិនចំណេញ។ តែយើងបានធ្វើ audit ឡើងវិញតែប៉ុណ្ណោះ ព្រោះកន្លែងដែលយើងបោះឆ្នាំ២០១២ ត្រូវចាក់ដីច្រើនណាស់ ពេលនោះបារាំងអត់ព្រមចាក់ដី ទៅបោះបង្គោលនៅកន្លែងផ្សេងដែលធ្វើឱ្យគម្លាតព្រំដែនចូលមកក្នុងដីយើងវិញ។ ពេលនេះវៀតណាមមិនមែនបាត់ដីទេ គ្រាន់តែយើងទៅយកបង្គោល ហ្នឹងទៅបោះឱ្យចំកន្លែងដើម។ បង្គោលថ្មីដែលយើងបោះជាមួយវៀតណាម ក៏ត្រូវធ្វើឱ្យត្រឹមត្រូវរវាងផែនទីជាមួយនឹងបង្គោលជាក់ស្តែង។ បើទោះបីជាមានការហត់នឿយបន្តិច ក៏យើងត្រូវតែរួមគ្នាដើម្បីលើកបង្គោលហ្នឹងទៅដាក់កន្លែងត្រឹមត្រូវ។ បង្គោលមួយចំនួនបោះ តាំងពីឆ្នាំមួយពាន់ប្រាំបីរយប៉ែត្រប្លាយ វាចាស់ហើយ។ បើដាក់ទៅវិញក៏ត្រូវធ្វើនីតិវិធីឱ្យបានត្រឹមត្រូវ និងមានតម្លាភាព។ អញ្ចឹងចំណុចនេះ គឺផ្ទៀងផ្ទាត់ឱ្យបានច្បាស់រវាងផែនទីជាមួយនឹងដីជាក់ស្តែង។ ឥឡូវផែនទីជាតិទុកថាដូចរឿងចប់ទៅហើយ មិនចាំបាច់ទៅផ្ទៀងជាមួយអ្នកណាទៀតទេ ព្រោះផែនទីនេះវាផ្លូវការ ហើយអ្នកណាហ៊ាននិយាយផែនទីក្លែងក្លាយ គឺទៅអនុវត្តច្បាប់ទៅ ប៉ុន្តែបញ្ហាដែលស្ថិតនៅ គឺបញ្ហាបោះបង្គោល។

**ទី៣. បន្តការចរចាជាមួយភាគីវៀតណាមដោយហ្មត់ចត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតលើបណ្តាចំណុចដែលមិនទាន់ដាច់ស្រេចទាំងឡាយ និងលើតំបន់ដែលត្រូវដោះដូរ ដោយឈរលើគោលការណ៍ស្មើទៅស្មើមក ទៅតាមលក្ខណៈភូមិសាស្ត្រ និងតាមស្ថានភាពដី ស្របតាមការអនុញ្ញាតនៃសន្ធិសញ្ញាបំពេញបន្ថែម និងអនុស្សរណៈយោគយល់ឆ្នាំ២០១១**

គោលការណ៍គន្លឹះនៅទីនេះ គឺធានាឱ្យបានដាច់ខាតថា កម្ពុជាមិនបាត់បង់ទឹកដីរបស់ខ្លួនឡើយ សូម្បីតែមួយម៉ែត្រក្រឡាក៏ដោយ។ ខណៈដែលការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនមិនទាន់ត្រូវបញ្ចប់ទាំងស្រុងទេនោះ រាជរដ្ឋាភិបាលនឹងបន្តធានាឱ្យបានល្អប្រសើរនូវកិច្ចសហការខ្ជាប់ខ្ជួនជាមួយភាគីវៀតណាម ក្នុងការរក្សាស្ថានភាពនៃការគ្រប់គ្រងតាមអ្វីដែលមានក្នុងពេលបច្ចុប្បន្ន និងតាមខ្សែបន្ទាត់ព្រំដែន តាមសេចក្តីប្រកាសរួមចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៥។ ចំណុចនេះ ខ្ញុំសូមបញ្ជាក់បន្តិច អនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ២០១១ អនុញ្ញាតឱ្យយើងធ្វើការដោះដូរ១ទៅ១មក។ មូលហេតុគឺងាយយល់យ៉ាងដូច្នេះ កន្លែងខ្លះ

បារាំងគូសផែនទីយកភូមិខ្មែរដាក់ឱ្យទៅវៀតណាម កន្លែងខ្លះបារាំងគូសផែនទីយកដីវៀតណាមដាក់មកនៅខាងខ្មែរ។ អញ្ចឹងបើសិនជា យើងរើភូមិរបស់កម្ពុជាចេញមកក្នុងដីខ្មែរ ឬកាត់ភូមិហ្នឹងទៅឱ្យដីវៀតណាម គឺមិនស្របទេ។ ដូចការជាក់ស្តែង ភូមិថ្លុកត្រាច របស់សម្តេច **ហេង សំរិន** ត្រូវរកវិធីដោះដូររកកន្លែងផ្សេង ដើម្បីរក្សាទុកនូវភូមិរបស់សម្តេច **ហេង សំរិន**។ ដូច្នេះគោលការណ៍១ទៅ១មកនេះ ត្រូវធ្វើឱ្យបានច្បាស់។ នេះទាមទារឱ្យមានភាពហ្មត់ចត់ ធ្វើយ៉ាងដូច្នេះ ដើម្បីធានាថា ដីដែលប្រជាពលរដ្ឋកំពុងបង្កបង្កើនផល និងភូមិកររបស់ពួកគាត់មិនត្រូវបានបាត់បង់ទេ។ វៀតណាមត្រូវរកដីឱ្យយើង យើងត្រូវរកដីឱ្យវៀតណាមនៅកន្លែងផ្សេង។ ដំបូងបំផុតយើងបានឯកភាពគ្នាជាមួយវៀតណាម រកក្នុងក្របខណ្ឌខេត្ត បើរកក្នុងក្របខណ្ឌខេត្តមិនបាន ត្រូវរកនៅកន្លែងផ្សេង ធានាឱ្យផ្ទៃក្រឡាទៅវិញទៅមក គឺទំហំប៉ុនគ្នា។ មួយទៀត ចំណុចទាំង៧ ដែលនៅសេសសល់ ដែលមាននៅក្នុងលិខិតរបស់ខ្ញុំជូនទៅនាយករដ្ឋមន្ត្រីវៀតណាម នៅតែជាប្រធានបទបន្តការពិភាក្សានៃគណៈកម្មការចម្រុះព្រំដែនកម្ពុជា-វៀតណាម ដែលក្នុងនោះមានទាំងតំបន់ដាក់ដាំ ដាក់ហ៊ុតផងដែរ។ ព្រមពេលដែលយើងបន្តការងារបោះខណ្ឌសីមា បោះបង្គោលព្រំដែនមិនទាន់ចប់ទេ ត្រូវខិតខំសហការជាមួយភាគីវៀតណាមទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រក្សាស្ថានភាពដដែលនៅតាមតំបន់ព្រំដែន។ ត្រូវធ្វើកិច្ចការងារនេះ តាមរយៈកិច្ចសហប្រតិបត្តិការល្អ មិនមែនគ្រាន់តែតាមព្រំដែនកម្ពុជា-វៀតណាមទេ ព្រំដែនជាមួយថៃ ព្រំដែនជាមួយឡាវ ក៏ត្រូវធ្វើដូចគ្នា។ សម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ បងប្អូនជនរួមជាតិជាទីស្នេហា ខ្ញុំព្រះករុណាខ្ញុំ ពិតជាយល់ច្បាស់ ដោយគ្មានការស្រមើស្រមៃទេថា អ្នកនយោបាយប្រឆាំងនៅតែបន្តយកបញ្ហាព្រំដែន ដែលជាបញ្ហារសើបបំផុតរបស់ប្រទេសជាតិ មកធ្វើអាជីវកម្មនយោបាយ ក្នុងគោលដៅវាយប្រហារមកលើរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ដើម្បីផលប្រយោជន៍នយោបាយរបស់ខ្លួន។ ដូចខ្ញុំព្រះករុណាខ្ញុំធ្លាប់បានលើកឡើងជារឿយៗមកហើយថា នេះមិនមែនជារឿងប្លែក និងថ្មីសម្រាប់កម្ពុជានេះទេ យុទ្ធសាស្ត្របែបនេះធ្លាប់ត្រូវបានគេយកមកប្រើប្រាស់រួចមកហើយ នៅក្នុងប្រវត្តិសាស្ត្រនយោបាយរបស់កម្ពុជា។ ដូចដែលគេទម្លាក់**ព្រះនរោត្តម សីហនុ** នៅឆ្នាំ១៩៧០ ក៏គេបានប្រើប្រាស់បញ្ហាព្រំដែន ដោយចោទប្រកាន់**សម្តេចព្រះនរោត្តម សីហនុ** សម្តេចឪ សម្តេចតា សម្តេចតាទួតនៃយើងថា ព្រះអង្គលក់ដីឱ្យវៀតណាមដែរ។ ដូច្នេះ វាមិនមែនជាបញ្ហាថ្មីទេ តែឥឡូវនេះក៏មានចំណុចថ្មីសម្រាប់ដោះស្រាយចំពោះពួកអ្នកទាំងនេះ តាមវិធានការណ៍ផ្លូវច្បាប់។ ដូច្នេះ បើទោះបីជាមានការពន្យល់បំភ្លឺលើកនេះថែមក៏ដោយ ថែមទៀតក៏ប្រហែលជាអ្នកនយោបាយទាំងនោះ នៅតែធ្វើមិនយល់ដដែល។ យ៉ាងណាក៏ដោយ គោលដៅចម្បងរបស់រាជរដ្ឋាភិបាលនៅពេលនេះ គឺការផ្តល់នូវការបំភ្លឺដល់ជនរួមជាតិកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ទាំងនៅក្នុង និងក្រៅប្រទេស ឱ្យបានជ្រាបអំពីគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈមោះមុត និងក្នុងស្មារតីប្តូរផ្តាច់ឥតងាករេ ក៏ដូចជាភាពហ្មត់ចត់ និងការទទួលខុសត្រូវខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាព្រំដែនរវាងកម្ពុជា និងវៀតណាម សំដៅជម្រះនូវភាពមិនច្បាស់លាស់ទាំងឡាយ នៅក្នុងកិច្ចការដ៏ មានសារៈសំខាន់នេះ ក៏ដូចជារំលេចឱ្យឃើញផងដែរនូវគោលបំណង និងផលប្រយោជន៍នយោបាយនានា ដែលលាក់បង្កប់នៅពីក្រោយការចោទប្រកាន់ និងការញុះញង់ដដែលៗឥតឈប់ឈរពាក់ព័ន្ធនឹងបញ្ហានេះ។ មុននឹងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំសូមសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅ ចំពោះជនរួមជាតិ ទាំងនៅក្នុង និងក្រៅប្រទេស ដែលមានសុភវិនិច្ឆ័យខ្ពស់ ហើយបានមើលឃើញយ៉ាងច្បាស់នូវសច្ចភាពនៃការរស់ឡើងវិញ និងការរីកចម្រើនរបស់ប្រទេស

ជាតិ ព្រមទាំងផ្តល់ជំនឿ និងការគាំទ្រដ៏ធំធេងចំពោះរាជរដ្ឋាភិបាល ក្នុងបេសកកម្មជាប្រវត្តិសាស្ត្ររបស់ខ្លួន នៅគ្រប់ដំណាក់កាល ហើយរយៈពេលចុងក្រោយ ក៏បានផ្ញើនូវសារយ៉ាងច្រើនគាំទ្រចំពោះរាជរដ្ឋាភិបាលទៅលើវិធានការណ៍ទាំងឡាយដែលរាជរដ្ឋាភិបាលបាននិងកំពុងធ្វើទៅលើបញ្ហាផែនទី ក៏ដូចជាបញ្ហាទាក់ទិនជាមួយនឹងបញ្ហាព្រំដែននេះ ដែលមានផ្ញើទាំងនៅក្នុងប្រទេស និងមកពីក្រៅប្រទេសផងដែរ។ អរគុណចំពោះអ្នកទាំងឡាយដែលបានគាំទ្រជាមួយនឹងទង្វើនេះ។ ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រសិទ្ធពរ ថ្វាយព្រះពរប្រគេន និងជូនសម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ បងប្អូនជនរួមជាតិកម្ពុជាគ្រប់រូប សូមប្រកបដោយពុទ្ធព្រះពរ៤ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ! សូមអរព្រះគុណ!

*****_*****